# សម្ភាសន៍ជាមួយឈ្មោះ ជា ប៉ុនឡុង អាយុ៥៣ឆ្នាំ ភេទប្រុស

មុខងារខ្មែរក្រហមៈ   ធ្វើទាហាន

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

ស្រុកកំណើតនៅៈ ភូមិត្រពាំងជង្រុក ឃុំបរសែត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅៈ ភូមិអូរដារលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៥១:៥៤

៦១ ទំព័រ

ដានី :	លោកពូ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូៗឈ្មោះអីដែរ?

ប៉ុនឡុង :	ជា ប៉ុនឡុង ។

ដានី :	ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ប៉ុនឡុង :	សព្វថ្ងៃនេះអាយុ៥៣ឆ្នាំ ។

ដានី :	៥៣ឆ្នាំ?

ប៉ុនឡុង :	បាទ!

ដានី :	បាទ!សព្វថ្ងៃរស់នៅភូមិ ឃុំអីដែរ?

ប៉ុនឡុង :	សព្វថ្ងៃហ្នឹង?

ដានី :	បាទ!

ប៉ុនឡុង :	បាទ!សព្វថ្ងៃហ្នឹងអូរដារលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។

ដានី :	លោកពូមានស្រុកកំណើតនៅណាដែរ?

ប៉ុនឡុង :	ស្រុកកំណើតខ្ញុំហ្នឹងនិយាយតាំងពីភូមិមកមែន?

ដានី :	បាទៗ!

ប៉ុនឡុង :	ភូមិត្រពាំងជង្រុក ឃុំបរសែត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ដានី :	ឃុំបរសែតមិនមែននៅស្រុកបរសែតទេ?

ប៊ុនឡុង ៖ ព្រោះស្រុកបរសេតបច្ចុប្បន្ននេះ អញ្ចឹងពីមុនស្រុកបរសេតហ្នឹងជាឃុំបរសេតទេ ។

ដានី ៖ អ្ហូ!អញ្ចឹង?

ប៊ុនឡុង ៖ បាទ! គេទើបតែកាត់ក្រោយនេះទេ ។

ដានី ៖ លោកពូប្រពន្ធលោកពូគាត់ឈ្មោះអីដែរ?

ប៊ុនឡុង ៖ គឹម វើត ។

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

ប៊ុនឡុង ៖ គាត់អាយុ៥២ឆ្នាំ ។

ដានី ៖ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ប៊ុនឡុង ៖ ស្រុកកំណើតគាត់នៅខេត្តកណ្ដាល ។

ដានី ៖ ខាងខេត្តកណ្ដាល?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ឃុំ ស្រុកអីដែរនៅខេត្តកណ្ដាល?

ប៊ុនឡុង ៖ ភូមិរាំងដេក ឃុំគគីរធំ ។

ដានី ៖ អ្ហូរខាងគគីរធំ ។

ប៊ុនឡុង ៖ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ដានី ៖ បាទ!ពូសព្វថ្ងៃមានកូនចៅប៉ុន្មាននាក់ដែរ?

ប៊ុនឡុង ៖ បាទ!ខ្ញុំមានកូន៣នាក់ ។

ដានី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ប៊ុនឡុង ៖ ប្រុស២ ស្រី១ ។

ដានី ៖ ប្រុស២ ស្រី១ ធំៗអស់ហើយ?

ប៊ុនឡុង ៖ បាទ!មានគ្រួសារអស់ហើយ ។

ដានី ៖ អូរ!មានគ្រួសារអស់ហើយ?

ប៊ុនឡុង ៖ នៅតែមួយពៅទេ ។

ដានី ៖ អូរ!នៅតែពៅមួយទេ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ បាទ!ពូប្រកបរបរធ្វើអីដែរ?

ប៊ុនឡុង ៖ បាទ!ខ្ញុំប្រកបមុខរបរធ្វើចំការ ។

ដានី ៖ ធ្វើចំការ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ធ្វើចំការអាហ្នឹងធ្វើអីខ្លះហ្នឹង?

ប៊ុនឡុង ៖ បាទ!បើនិយាយទៅ អាហ្នឹងចំការ ហើយនឹងស្រែ វារួមគ្នា ព្រោះចំការដាំពោត ដាំដំឡូង ហើយផុតពីនេះហ្នឹងទៅខែស្រែ យើងធ្វើស្រែ ដាំស្រូវ ។

ដានី ៖ អូរ!បាទ ពូឪពុកម្ដាយ ឪពុកលោកពូគាត់ឈ្មោះអីដែរ?

ប៊ុនឡុង ៖ ឪពុកខ្ញុំស្លាប់បាត់ហើយ ។

ដានី ៖ បាទ!ឪពុកពូគាត់ស្លាប់ ស្លាប់ឆ្នាំណាទៅ?

ប៊ុនឡុង ៖ បាទ!ស្លាប់នោះខ្ញុំមិនដឹងជាឆ្នាំប៉ុន្មានទេ ដែលក្នុងអំឡុងពេលចន្លោះឆ្នាំពី៧៥ ម៉ោឆ្នាំ៧៩ ហ្នឹង ។

ដានី ៖ បាទ!ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ គាត់ឈ្មោះអីដែរ?

ប៊ុនឡុង ៖ គាត់ស្លាប់ហ្នឹង?

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដា ត្តម ។

ដានី ៖ ចុះម្ដាយ?

ប៊ុនឡុង ៖ ម្ដាយខ្ញុំនៅ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

ប៊ុនឡុង ៖ បាទ!ម្ដាយខ្ញុំឈ្មោះសេក ដាត់ ។

ដានី ៖ សេក ឌាត់?

ប៊ុនឡុង ៖ សេក ដាត់ ។

ដានី ៖ គាត់អាយុប៉ុន្មានហើយ?

ប៊ុនឡុង ៖ គាត់អាយុ៨០ជាង ។

ដានី ៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ប៊ុនឡុង ៖ ខ្ញុំមានបងប្អូនបង្កើត៤នាក់ ។

ដានី ៖ បាទ!ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ប៊ុនឡុង ៖ ប្រុសទាំងអស់ ។

ដានី ៖ ប្រុសទាំងអស់ម៉ង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អ៊ើ!ពូកូនទីប៉ុន្មាន?

ប៊ុនឡុង ៖ បាទ!ខ្ញុំកូនទី២ ។

ដានី ៖ កូនទី២ ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចុះកាលពីក្មេងៗពូបានរៀនសូត្រអីដែរ?

ប៊ុនឡុង ៖ កាលពីជំនាន់សង្គមរាស្ត្រនិយមហ្នឹង អាហ្នឹងម៉ាជំនាន់ហើយណាស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ខ្ញុំបានរៀនតែបានកំរិតទាប បើយើងនិយាយទៅថ្នាក់ទី១០ពីដើមស្មើនឹងយើងក្មេងថ្នាក់ទី៣ក្មេងឥឡូវហ្នឹង ។

ដានី ៖ បាទ!រៀននៅសាលាណា?

ប៊ុនឡុង ៖ បាទ!សាលានៅជាប់ភូមិនឹងឯង ។

ដានី ៖ បាទ!នៅជាប់ភូមិកំណើតហ្នឹងម៉ង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ គេហៅសាលាអីសាលាហ្នឹង?

ប៊ុនឡុង ៖ សាលាអីហើយទេ! ។

ដានី ៖ សាលាត្រពាំងជជ្រុកហ្នឹងឬមែនទេ?

ប៊ុនឡុង ៖ អត់ទេ!ហ្នឹងគេហៅសាលាអីទេ បើអនុវិទ្យាល័យពីដើមដែលខ្ញុំកើតទាន់ សម្តេចគាត់ដាក់ថា អនុវិទ្យាល័យសម្តេចឪប្រទាន ។

ដានី ៖ អ្អូ!

ប៊ុនឡុង ៖ ហើយដល់អាសាលាយើងរៀនចាប់ពីមុនដំបូងហ្នឹងទៅ ខ្ញុំមិនបាននេះទៀត ភ្លេចអាសាលាហ្នឹងទៀត ។

ដានី ៖ បាទ!ចុះពូឈប់រៀនឆ្នាំណា?

ប៊ុនឡុង ៖ បាទ!ឆ្នាំ៧០ហ្នឹងដែលកើតរដ្ឋប្រហារ ។

ដានី ៖ ឆ្នាំ៧០ហើយ ពូធ្វើអីទៀតទៅ?

ប៊ុនឡុង ៖ បាទ! ក្រោយពីកើតរដ្ឋប្រហារម៉ោ ខ្ញុំនៅវ័យក្មេងនៅជាមួយឪពុកម្ដាយហ្នឹង ។

ដានី ៖ នៅធ្វើអីនៅជាមួយឪពុកម្ដាយ?

ប៊ុនឡុង ៖ បាទ! ជួយធ្វើស្រែធ្វើអីហ្នឹងឯង ។

ដានី ៖ បាទ! អត់មានធ្វើអីទៀតទេ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ធ្វើស្រែ! ធ្វើស្រែរហូតដល់ឆ្នាំណាបានពូចេញពីផ្ទះ?

ប៊ុនឡុង ៖ បាទ! ធ្វើស្រែពីឆ្នាំ៧០ហ្នឹង ដល់ពាក់កណ្ដាលឆ្នាំ៧២ បានចូលជាកងទ័ព ។

ដានី ៖ ចូលកងទ័ព?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ពូចូលកងទ័ពហ្នឹង ពូស្ម័គ្រចិត្តចូលឬក៏យ៉ាងម៉េចកាលជំនាន់ហ្នឹង?

ប៊ុនឡុង ៖ ជំនាន់នោះ អាហ្នឹងយើងវានេះដែរ អាហ្នឹងយើងនិយាយបន្តិចទៅ បើយើងមិនស្ម័គ្រចិត្តចូលនៅជៀសតែចូលដដែល ។

ដានី ៖ អ្ហូ! អញ្ចឹងពូ ពូស្ម័គ្រចិត្ត ឬក៏មានគេចុចឈ្មោះឲ្យចូល?

ប៊ុនឡុង ៖ បាទ! ខ្ញុំនឹកឃើញថាអាហ្នឹងដូចគេមានចុះឈ្មោះចូលតម្រូវការ ។

ដានី ៖ តម្រូវការ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ កាលហ្នឹងនៅភូមិរបស់ លោកពូ ដូចថាក្មេងៗស្បាលៗលោកពូ ដូចថាស្បាលៗគ្នាហ្នឹងចូលទៅច្រើនឬទៅតែពូម្នាក់?

ប៊ុនឡុង ៖ បាទ! កាលហ្នឹងដែលមានឈ្មោះចូលហ្នឹង គឺចូលតាម ឧទាហរណ៍ថាមានតាមវគ្គតាម ស្មើ ។

ដានី ៖ តាមវគ្គតាមស្មើ?

ប៊ុនឡុង ៖ មួង៣នាក់ ។

ដានី ៖ បាទៗ! ស្មើពីណាពី?

ប៊ុនឡុង ៖ បាទ! អាហ្នឹង មិនដឹងពីខាងណា មិនដឹងពីខាងតំបន់ ពីខាងអីពេលដែលឆ្នាំ៧២អញ្ចឹងទៅគេមិនកើតធ្វើសង្គ្រាម ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងការរៀនសូត្រអត់មានទេ ផ្អាក់អស់ហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង : អញ្ចឹងតម្រូវការត្រូវធ្វើទាហាន អញ្ចឹងមានការ បើអ្នកមុនៗនឹងគេអ្នកស្ម័គ្រចិត្ត ។

ដានី : បាទ!

ប៊ុនឡុង : អញ្ចឹងបន្ទាប់ម៉ោ ក្រោយម៉ោទៀតអ្នកធំក៏គេមានអ្នកស្ម័គ្រចិត្ត អញ្ចឹងថាតម្រូវការក៏មានគេស្ម័គ្រចិត្តដូចតែគ្នាហ្នឹង ។

ដានី : បាទ!

ប៊ុនឡុង : បាទ!

ដានី : យើងស្ម័គ្រចិត្តហ្នឹងតាមរយៈភូមិឃុំ ឬតាមអង្គភាពយោធាម៉ង?

ប៊ុនឡុង : បាទ!អាហ្នឹងព្រោះស្ម័គ្រចិត្តតាមរយៈ ដែលថាការស្ម័គ្រចិត្តធ្វើកងទ័ពទី១ៈគេជំរុញយើងចូលជាកងទ័ពហើយ អញ្ចឹងឡើងតាមនេះ យកម៉ោបើថាស្រុកគេអាចបញ្ជូនទៅតំបន់ តំបន់គេថាបញ្ជូនទៅភូមិភាគទៀត ។

ដានី : បាទៗ!

ប៊ុនឡុង : អញ្ចឹងខ្ញុំចេញពីផ្ទះម៉ោនេះគឺ ចេញពីផ្ទះម៉ោ ម៉ោនៅកងភូមិភាគតែម្តង ។

ដានី : ភូមិភាគណា?

ប៊ុនឡុង : បាទ!អាហ្នឹងបើយើងនិយាយទៅ ភូមិភាគនិរតី ។

ដានី : អាហ្នឹងមិនមែនភូមិភាគបញ្ចឹមទេ?

ប៊ុនឡុង : មិនមែនទេ ។

ដានី : និរតី?

ប៊ុនឡុង : និរតី ។

ដានី : កាលហ្នឹងតំបន់អីគេ នៅភូមិភាគនិរតីនៅតាមស្រុកពូ?

ប៊ុនឡុង : ភូមិភាគនិរតីវាមានប៉ុន្មានតំបន់នោះ ។

ដានី : បាទ!ប៉ុន្តែកន្លែងលោកហ្នឹង តំបន់អីគេហ្នឹង?

ប្រពន្ធ : អាហ្នឹងតំបន់៣៣អី ។

ប៊ុនឡុង : កន្លែងបើនិយាយទៅកងទ័ពដូចរកកន្លែងកំណត់ថានៅម៉ាតំបន់អត់ឃើញ តំបន់ភូមិភាគពួកខាងភូមិភាគគេប៉ុន្មាន ឲ្យទាហរណ៍ថាភូមិភាគនិរតី អញ្ចឹងវាមានប៉ុន្មានតំបន់ហ្នឹងគឺចល័តគ្រប់តែតំបន់ហ្នឹង ។

ដានី : បាទ!ចុះកាលពីស្រុកភូមិពូដែលពូ ចូលម៉ោធ្វើកងទ័ពនៅភូមិភាគហ្នឹង កាលហ្នឹងគ្នាប៉ុន្មាននាក់ទៅពូចាំឈ្មោះទេ ពីភូមិពូហ្នឹង?

ប៊ុនឡុង ៖ បាទ! ម៉ោម៉ាស្រុកខ្ញុំហ្នឹងគឺ ដូចភ្លេចឈ្មោះគេអស់ហើយ ហើយម្យ៉ាងដល់ឥឡូវគេស្លាប់អស់ទៀត ។

ដានី ៖ អ្ហូ! ស្លាប់អស់ហើយ?

ប៊ុនឡុង ៖ បាទ! គេមិនស្លាប់ធ្វើសង្គ្រាមទេ គេស្លាប់ដោយថា ដែលឆ្នាំ៧៥ចប់ហើយម៉ោផ្ទះវិញហ្នឹងឈឺ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ បាទ! ហើយដោយតាំងពីហ្នឹងម៉ោ ខ្ញុំភ្លេចឈ្មោះគេ ព្រោះថាយើងវាយូរពេក ។

ដានី ៖ បាទៗ! អញ្ចឹងពេលពូចេញពីផ្ទះអម៉ោ ម៉ោនៅកងភូមិភាគហ្នឹង កាលហ្នឹងយ៉ាងម៉េចទៅពេលម៉ោនៅ យើងហាត់កងទ័ព ឬក៏យ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ! អាហ្នឹងអត់មានអីទេ តួនាទីកងទ័ពមានតែហាត់ បាទ!

ដានី ៖ កាលហ្នឹងហាត់នៅណាទៅ ហាត់នៅកន្លែងកងភូមិភាគហ្នឹងនៅណា?

ប៊ុនឡុង ៖ បាទ! នេះមិនមែនហាត់ដូចសម័យយើងឥឡូវមានកន្លែងមាននេះទេ ខ្ញុំសូមបញ្ជាក់ត្រង់ប៉ុណ្ណេះ ការហាត់ការរឹករឺននេះក្រោយពី ឧទាហរណ៍ថាយើងបើយុទ្ធនាការទីតាំងណាមួយហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ចប់យុទ្ធនាការម៉ោ ដកនៅកន្លែងណា គឺហាត់កន្លែងហ្នឹង ២-៣ថ្ងៃទៅមានការបើយុទ្ធការនៅត្រង់ណាយើងទៅធ្វើទៀត ចប់ពីយុទ្ធការ អញ្ចឹងអត់មាននៅម៉ាកន្លែងបានទេ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ បាទ! អាហ្នឹងលើកលែងតែពេលសម្រាក គឺយើងហាត់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ! ម៉ាកន្លែង៣-៤ខែណា អត់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងថា២-៣ថ្ងៃអញ្ចឹងទៅ មានការចាំបាច់ថាត្រូវទៅណេះណោះទៅ ទៅធ្វើហ្នឹងទៅចប់រឿងហ្នឹងហើយបានម៉ោវិញ មានពេលសម្រាកអាហ្នឹងហាត់ខ្លះទៅ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ រួមផ្សំនឹងការដាក់ស្ដែង ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៈ បាទ!

ដានី ៈ កងទ័ពហ្នឹងពូ ដូចថាគេហៅកងអី កងវរៈសេនាតូចវរៈសេនាធំ កងពលអី លេខប៉ុន្មានដែរ?

ប៊ុនឡុង ៈ ចេះខ្ញុំនៅចាំបាន ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ ក្រោយពីខ្ញុំចេញពីផ្ទះទៅ ចូលអង្គភាពខ្ញុំនៅកងអនុសេនាធំលេខ៥១ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ!វរៈសេនាតូចលេខ៣២០ វរៈសេនាធំលេខ១៨ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ កងពលទី២ ប្រចាំភូមិភាគនិរតី ។

ដានី ៈ បាទ!ចូលទៅនៅក្នុងកងពលហ្នឹងបណ្ដោយ?

ប៊ុនឡុង ៈ បាទ!

ដានី ៈ កន្លែងទិសកងពលហ្នឹងនៅម្ដុំណា ទិសដៅជិនាញចូលភ្នំពេញហ្នឹង?

ប៊ុនឡុង ៈ បាទ!អានេះកន្លែងដែលលោកប្អូនសួររកកន្លែង ព្រោះជំនាន់នោះ តាមអង្គភាពមួយៗការបែងចែកតាមមុខសញ្ញា ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ អញ្ចឹងកន្លែងកងពល គេមិនអនុញ្ញាតឲ្យយើងដឹងក៏មាន ។

ដានី ៈ អូ!

ប៊ុនឡុង ៈ គេដាក់កន្លែងណាអីកន្លែងណា យើងអាដែងណែតាមអង្គភាពតូចៗយើងមិនអាចដឹងគេទេ ។

ដានី ៈ បាទៗ!ដូចថាកាលហ្នឹង ទិសដៅទី១ដូចគាត់ត្រូវចាំត្រឹមនេះ ដល់ត្រឹមនេះ កងពលទី២ពីត្រឹមនេះដល់ត្រឹមនោះទៀត កងពលទី៣ពីត្រឹមនេះអញ្ចឹងពូ?

ប៊ុនឡុង ៈ បាទ!អញ្ចឹងបើនិយាយកន្លែងប្រចាំម៉ងខ្ញុំអត់ដឹងទេណា! ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ តែបើនៅក្នុងតំបន់ភូមិភាគនិរតីហ្នឹង ទឹកដីហ្នឹងកងពលទី២គឺប្រឈរចាំនៅក្នុងភូមិភាគហ្នឹងម៉ង ។

ដានី ៈ បាទ!

ប៊ុនឡុង ៖ តែកន្លែងគេមិនដាក់គេដាក់ត្រង់ណា អីត្រង់ណាទេ គេវាមិនឲ្យយើងដឹង ។

ដានី ៖ បាទ!កាលហ្នឹងកាលយើងវៃចូលទីក្រុងភ្នំពេញ យើងវៃចូលពីច្រកណា?

ប៊ុនឡុង ៖ បាទ!អាហ្នឹងយើងនិយាយទៅ ពីខាងត្បូងភ្នំពេញ ។

ដានី ៖ ពីខាងត្បូងពីខាងស្រុក?

ប៊ុនឡុង ៖ ខាងត្បូងឈានខាងលិចហ្នឹង ។

ដានី ៖ ខាងកណ្តាលស្ទឹងខាងអី ស្រុកកណ្តាលស្ទឹងហ្នឹង?

ប៊ុនឡុង ៖ វាចាក់ទងមុំម៉ាជួរវត្តស្លែង ។

ដានី ៖ ម៉ាជួរវត្តស្លែង ។

ប៊ុនឡុង ៖ ស៊ីកកន្ទួតម៉ាជួរវត្តស្លែងហ្នឹង ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!ស៊ីងកន្ទួតម៉ាជួរវត្តស្លែងហ្នឹង ។

ដានី ៖ គ្នាច្រើនទេ កាលហ្នឹងកងពលទី២ ?

ប៊ុនឡុង ៖ បាទ!អាហ្នឹងជំនាន់នោះកងម៉ាកងគឺពេញ ។

ដានី ៖ ពេញៗ?

ប៊ុនឡុង ៖ បាទ!បើម៉ាអនុសេនាធំ អាហ្នឹងគេថាម៉ាកងវរយ នោះណា៎!

ដានី ៖ បាទ!ម៉ាកងវរយ ។

ប៊ុនឡុង ៖ បាទ!វាមានគ្នាពី១១០ទៅ១២០នាក់ ។

ដានី ៖ បាទ!ម៉ាអនុសេនាធំ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ កងតូច អុស៎អើម៉ាវរៈសេនាតូចកងតូច?

ប៊ុនឡុង ៖ ម៉ាវរៈសេនាតូចគឺវាមាន៤អនុសេនាធំ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ បាទ!ហើយបើម៉ាអនុសេនាធំវាមាន៣អនុសេនាតូច ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!ហើយក្នុងម៉ាអនុសេនាតូចហ្នឹងវាមាន៣ក្រុម ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!តែមនុស្សពេញៗ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ១២ដួនកាល១៥ ។

ដានី ៖ បាទៗ!វាជិត៥០នាក់ដែរ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ៣០-៤០នាក់ហើយ?

ប៊ុនឡុង ៖ បាទ!៣០-៤០នាក់ហើយ ម៉ាកងតូចៗនោះ ។

ដានី ៖ បាទ!កាលហ្នឹងកងពលទី២ប្រធានគាត់ឈ្មោះអីដែរ?

ប៊ុនឡុង ៖ បាទ!ខ្ញុំអត់បានស្គាល់ឈ្មោះអីប៉ុន្មានទេ!គេមិនសូវផ្សព្វផ្សាយរឿងឈ្មោះមេៗផង ។

ដានី ៖ អ្ហូ!កាលនៅវរៈសេនា អនុសេនាធំ៥១ហ្នឹង ពូធ្វើប្រធាន?

ប៊ុនឡុង ៖ អត់ទេ!ខ្ញុំជាយុទ្ធជន ។

ដានី ៖ យុទ្ធជន?

ប៊ុនឡុង ៖ បាទ!អាហ្នឹងនិយាយឲ្យចំម៉ងទៅ មិននេះទៀត យើងជានិរសាររបស់កងអនុសេនាធំ ។

ដានី ៖ និរសា?

ប៊ុនឡុង ៖ បាទ!

ដានី ៖ និរសាហ្នឹងគេធ្វើអីខ្លះទៅ?

ប៊ុនឡុង ៖ បាទ!និរសានេះមានការងារនៅជាមួយមេ ហើយឧទាហរណ៍ថាមានបទបញ្ជានៅក្នុងសមរភូមិគឺយើងឡើងប្រាប់តាម អាដែងណែំជួរខ្សែត្រៀម ។

ដានី ៖ បាទ!គាត់ឈ្មោះអីប្រធាន អនុប្រធានធំរបស់ពូ?

ប៊ុនឡុង ៖ ប្រធានអនុសេនាធំ បាទ!អញ្ចឹងដែលខ្ញុំនៅជាមួយគាត់ហ្នឹង ខ្ញុំចូលទៅនៅជាមួយគាត់ ហ្នឹងគាត់ឈ្មោះ អួរ ទ្រី ។

ដានី ៖ អួរ ទ្រី?

ប៊ុនឡុង ៖ បាទ!តែមិនដឹងថាគាត់ស្លាប់ឬនៅទេ គាត់កាលនោះគាត់ចាស់ដែរហើយនោះ ។

ដានី ៖ អត់ដែលជួបគាត់ទេ?

ប៊ុនឡុង ៖ អត់ទេ!អត់ដែលជួបទេ ទល់ឥឡូវនេះ ។

ដានី ៖ បាទ!បែកគាត់ឆ្នាំណាដែរ?

ប៊ុនឡុង ៖ បែកគ្នាក្រោយពីយើងចប់សង្គ្រាម ។

ដានី ៖ ចប់ឆ្នាំ៧៥?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ អញ្ចឹងគាត់មានគួនាទីទៅផ្សេងទៅ ខ្ញុំម៉ោផ្សេងម៉ោ ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ អញ្ចឹងយើងនៅបែកគ្នា ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ ជំនាន់នោះនៅដូចថា កម្មាភិបាលត្រូវដកទៅនេះទៅនោះខ្វះទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងបានបែកគ្នា តាំងពីនោះម៉ោ ។

ដានី ៖ បាទ!គាត់អ្នកស្រុកភូមិពូដែរឬក៏មិនមែនទេ?

ប៊ុនឡុង ៖ ខ្ញុំអត់បានដឹងដែរ ។

ដានី ៖ អត់ដឹងដែរ?

ប៊ុនឡុង ៖ បាទ!មិនដឹងជាគាត់នៅស្រុកណា នៅភូមិណា ឃុំណាខ្ញុំអត់ដឹងដែរ ។

ដានី ៖ បាទ!ចុះពូនៅក្នុងកងអនុសេនាធំ៥១ហ្នឹងរហូតដល់បែកឆ្នាំ៧៥ ឬក៏មានផ្លាស់ប្តូរអី ដែរ?

ប៊ុនឡុង ៖ បាទ!ខ្ញុំនៅទល់តែបែកឆ្នាំ៧៥ ។

ដានី ៖ បាទ!កាលហ្នឹងដូចថា អនុសេនាធំ៥១កងពលទី២ហ្នឹង យើងនៅពូថានៅម៉ាជួរខាង សមរភូមិទិស ខាងវត្តស្វែង ខាងស្ទឹងកន្ទួតហ្នឹងឬក៏ម៉េច?

ប៊ុនឡុង ៖ បាទ!អាហ្នឹងសមរភូមិយើងនិយាយទៅ តាកែវក៏វៃ កំពតក៏វៃ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ធ្លាក់មកដល់វាលរិញ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ កំពង់សិលា ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ម៉ាជួរតាមដងផ្លូវលេខ៤ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ កំពង់ស្ពឺ ។

ដានី ៖ បាទ!

ប៊ុនឡុង : និយាយទៅភូមិនិរតី ។

ដានី : កាលហ្នឹងដូចថា ពេលដែលយើងវៃ កាលជំនាន់ហ្នឹងជួបប្រទះឧបសគ្គអីយ៉ាងម៉េចខ្លះទៅ?

ប៊ុនឡុង : បាទ!ឧបសគ្គវាមាន វាមិនអត់ទេ មានត្រង់ថាការធ្វើសង្គ្រាម យើងជួបឧបសគ្គនឹងការគឺចូលប្រយុទ្ធក្នុងសមរភូមិហ្នឹង ។

ដានី : បាទ!

ប៊ុនឡុង : បាទ!វាឧបសគ្គនឹងគ្រាប់ហ្នឹង បាទ!រឿងឈ្នះរឿងចាញ់អីវាជារឿងធម្មតាទេ ធម្មតាដែលយើងធ្វើសង្គ្រាមហើយវាតែងតែមានឈ្នះមានចាញ់ ។

ដានី : បាទ!

ប៊ុនឡុង : បាទ!

ដានី : កាលហ្នឹងយើងប្រយុទ្ធអីជាមួយខាងទាហានលន់ ណុល?

ប៊ុនឡុង : បាទ!

ដានី : មានវៃជាមួយយួនទេ កាលហ្នឹង?

ប៊ុនឡុង : អត់មានទេ!

ដានី : បាទ!

ប៊ុនឡុង : បាទ!

ដានី : បាទ!ចុះពូកាលជំនាន់ហ្នឹងអត់មានត្រូវរបួសអីទេ កាលជំនាន់ពី៧២ដល់៧៥?

ប៊ុនឡុង : បាទ!កាលពី៧០ដល់៧៥ខ្ញុំអត់ដែលត្រូវរបួសអីទេ ។

ដានី : អត់ដែលទេ?

ប៊ុនឡុង : បាទ!

ដានី : ចុះកាល ដូចថាពេលធ្វើកងទ័ពហ្នឹងខស្សាហ៍បានមកលេងផ្ទះ លេងអីបុអត់ តាំងពីយើងចេញម៉ោធ្វើកងទ័ព?

ប៊ុនឡុង : ចេះសុំថាការមកលេងផ្ទះ ជំនាន់នោះមេអនុញ្ញាតឲ្យម៉ោដូចថាវាមិនញឹកញាប់ទេ ។

ដានី : បាទ!

ប៊ុនឡុង : ព្រោះយើងមានភារកិច្ចកំពុងតែប្រយុទ្ធ ។

ដានី : បាទ!

ប៊ុនឡុង ៖ អញ្ចឹងការមកលេងផ្ទះនេះ មានម៉ាដងម៉ាកាល យើងចប់ពីក្រុង បែកពីក្រុងភ្នំពេញ ហ្នឹងគឺបានមកលេង មេឲ្យម៉ោលេង ក្នុងចាប់កំឡុងឆ្នាំ៧៥ហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ បាទ!អញ្ចឹងទាល់តែបែកឆ្នាំ៧៥បានម៉ោលេងផ្ទះបានមួយដង?

ប៊ុនឡុង ៖ អ៊ូ!អាហ្នឹងខ្ញុំឆ្លើយនេះបន្តិច អព្ភោះដែរ មុនបែក៧៥ខ្ញុំបានចូលផ្ទះចូលអីដែរ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ដោយថាកងទ័ពមានភារកិច្ច ដែលម៉ោពីសមរភូមិវិញម៉ោ ទៅដាក់នៅទីងភូមិក្បែរនឹងភូមិខ្ញុំ អញ្ចឹងយើងអាចបានចូលទៅផ្ទះ បាទ!កន្លែងហ្នឹង ។

ដានី ៖ បាទៗ!អញ្ចឹងដល់ពេលបែកភ្នំពេញឆ្នាំ៧៥ហ្នឹងយ៉ាងម៉េចទៀត លោកពូនៅអង្គភាពដដែល ឬក៏មានការផ្លាស់ប្តូរអីយ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ!ក្រោយពីបែកអង្គភាព អ៊ុះ!បែកភ្នំពេញម៉ោខ្ញុំនៅអង្គភាពដដែល អញ្ចឹងកាល នោះអង្គភាពដូចថាអត់ បើយើងឈរជើងទប់នឹងម៉ាកន្លែងវ៉ា អត់មាននេះ អញ្ចឹងគេ រុញអង្គភាពឲ្យម៉ោនៅ ឲ្យមកជួយធ្វើស្រែប្រជាពលរដ្ឋ បាទ!ឆ្នាំ៧៦ ។

ដានី ៖ ធ្វើស្រែនៅណាទៅ?

ប៊ុនឡុង ៖ បាទ!ធ្វើស្រែហ្នឹង យើងនៅស្រុកកោះអណ្តែត ម្តុំកោះអណ្តែតហ្នឹងៗ ។

ដានី ៖ បាទ!កោះអណ្តែតខាងតាកែវ?

ប៊ុនឡុង ៖ បាទៗ!

ដានី ៖ ខ័ណ្ឌដល់ព្រំដែនយួនហើយហ្នឹង?

ប៊ុនឡុង ៖ បាទៗ!ហ្នឹងហើយជួយធ្វើស្រែប្រជាពលរដ្ឋតាមព្រំដែនហ្នឹង ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ បាទ!ធ្វើទាំងស្រែប្រាំង ជួយទាំងស្រែវស្សា ។

ដានី ៖ អ៊ូ!អញ្ចឹងម៉េចបានកងទ័ព គេឲ្យទៅធ្វើស្រែទៅដល់ហ្នឹងវិញ?

ប៊ុនឡុង ៖ បាទ!នេះខ្ញុំសូមបញ្ជាក់ខាងដើមថា កម្លាំងដែលត្រូវការពារ ការពារ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រំដែន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ កម្លាំងដែលនៅសល់គឺយើង ជួយធ្វើស្រែប្រជាពលរដ្ឋ ព្រោះអាហ្នឹងវាជាការចាំបាច់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រោះជាទូទៅគ្រប់អង្គភាពទាំងអស់ ដកតែកម្លាំងការពារទៅ នៅសល់ប៉ុន្មានគឺឲ្យចុះជួយធ្វើស្រែប្រជាពលរដ្ឋ ។

ដានី ៖ បាទ!អញ្ចឹងដល់ពេលបែកឆ្នាំ៧៥អង្គភាពរបស់ពូ ផ្លាស់ទៅកោះអណ្ដែតទាំងអស់?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ទៅខាងការពារព្រំដែននៅខាងតាកែវនោះវិញ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ នៅក្នុងភូមិភាគដដែល?

ប៊ុនឡុង ៖ បាទ!អាហ្នឹងនៅក្នុងភូមិភាគដដែលហ្នឹង ។

ដានី ៖ អ្ហូ!ទាំងកងពលអីទៅនៅខាងព្រំដែនខាងកោះអណ្ដែតហ្នឹង?

ប៊ុនឡុង ៖ បាទ!តែមិនជាកងពលគេដាក់នៅណាទេណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!តែគ្រប់កងវរៈទាំងអស់គឺទៅហ្នឹង ។

ដានី ៖ អ្ហូ!គ្រប់កងវរៈទៅ ហ្នឹងទាំងអស់?

ប៊ុនឡុង ៖ បាទ!

ដានី ៖ តែពូនៅអនុសេនាធំលេខ៥ ១ដដែល?

ប៊ុនឡុង ៖ បាទ!តែក្រោយម៉ោ ចង់ដាច់ឆ្នាំ៧៦ហ្នឹង គឺគ្រាន់តែផ្លាស់ពីអង្គភាពមួយ ម៉ោអង្គភាពមួយ គ្រាន់តែថាពីរនៅក្នុងវរៈសេនាធំតែមួយដូចតែគ្នា ដដែលទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គ្រាន់តែផ្លាស់ពីវរៈសេនាតូច ៣២០ម៉ោ៤០៧វិញ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ បាទ!តែវរៈសេនាធំ១៤ជាមួយគ្នាដដែល ។

ដានី ៖ បាទ!អ្ហូនៅកងពលទី២ដដែល?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អត់មានដូរលេខកងពលអីទេ?

ប៊ុនឡុង ៖ អត់ទេ!

ដានី ៖ អូ!ពីព្រោះកងពលខ្លះដូចខ្ញុំធ្លាប់ជួប ធ្លាប់អើសម្ភាសន៍ជាមួយអ៊ំពូមីងគាត់ច្រើនតែដូរ គាត់ច្រើនតែបែកភ្នំពេញឆ្នាំ៧៥ហ្នឹង គាត់ច្រើនតែដូរឈ្មោះលេខកងពល ផ្លាស់ពីភូមិភាគទៅ មជ្ឈិមអញ្ចឹង ទៅសេនាធិការទេ?

ប៊ុនឡុង ៖ អាហ្នឹងមិនទាន់ដល់រឿង ។

ដានី ៖ អូ!

ប៊ុនឡុង ៖ តិចទៀត ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អញ្ចឹងខ្ញុំផ្លាស់ម៉ោ៨០៧នេះ ខ្ញុំនៅប្រឈរជើងប្រចាំការណ៍នៅម៉ាដួរភ្នំដិន ។

ដានី ៖ អូ!បាទនៅម៉ាដួរភ្នំដិន?

ប៊ុនឡុង ៖ បាទ! អញ្ចឹងឆ្នាំ៧៨ដែលយើងមានប្រទូសសារាយតាមព្រំដែន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ជាមួយនឹងយួន ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អញ្ចឹងខ្ញុំនឹង នៅហ្នឹងបានទៅដល់ឆ្នាំ៧៨ អាចចូលទៅដល់ខែ៨-ខែ៩ក្នុងឆ្នាំ៧៨ខ្ញុំផ្លាស់ពីអង្គភាពកងពលលេខ២ហ្នឹងម៉ោ ម៉ោស្វាយរៀង បាទ! ។

ដានី ៖ ឆ្នាំប៉ុន្មាន ឆ្នាំ?

ប៊ុនឡុង ៖ ឆ្នាំ៧៨ ។

ដានី ៖ ខែប៉ុន្មាន ខែ?

ប៊ុនឡុង ៖ អាចជាខែ៨ខែអីហ្នឹងឯង ។

ដានី ៖ ផ្លាស់ពីកងពលលេខទីម៉ោស្វាយរៀងវិញ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ មូលហេតុអីបានផ្លាស់ពី?

ប៊ុនឡុង ៖ បាទ!អាហ្នឹងយើង៧៨ យើងមានការប្រទូសស្រារាយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តាមព្រំដែនណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងចាប់ពីហ្នឹងមៅ គឺសង្គ្រាមមានកើតទៀតហើយ តាមព្រំដែន រវាងខ្មែរហើយនឹងយួន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងគេត្រូវដូរឲ្យខ្ញុំហ្នឹង មិនថាតែចំពោះខ្ញុំទេ ក្នុងអង្គភាព គ្រប់អង្គភាព ម៉ាអង្គ ២-៣នាក់ៗហ្នឹងគឺម៉ោស្វាយរៀងហ្នឹង ។

ដានី ៖ ម៉ោស្វាយរៀង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អញ្ចឹងកងពលទី២អត់មានផ្លាស់ពីខាងភ្នំដិន ពីខាងកោះអណ្ដែតហ្នឹងមៅស្វាយរៀងទាំងអស់ទេ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដកតែម៉ាចំនួនទេ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អញ្ចឹងកងពលគេនៅដដែល?

ប៊ុនឡុង ៖ បាទ!នៅដដែល ។

ដានី ៖ បាទ!កាលហ្នឹងប្រធានកងពលទី២ឈ្មោះអីដែរ កាលនៅភ្នំឌិន?

ប៊ុនឡុង ៖ បាទ!កាលហ្នឹងខ្ញុំ ប្រធានហ្នឹងគាត់អត់ដែល ហ៊ីចាំអត់បានទេ ប៉ុនឥឡូវគាត់ស្លាប់បាត់ហើយហ្នឹង ។

ដានី ៖ អ្ហូ!គាត់ទឹមស្លាប់ដែរ?

ប៊ុនឡុង ៖ គាត់យើងមុនសមាហរណកម្មហ្នឹង ។

ដានី ៖ អ្ហូ!គាត់ឈ្មោះអីទៅ?

ប៊ុនឡុង ៖ ប្រធានកងពលទី២ហ្នឹង ឈ្មោះ វ៉ែន ។

ដានី ៖ បាទ?

ប៊ុនឡុង ៖ ឈ្មោះ វ៉ែន ។

ដានី ៖ ឈ្មោះ វ៉ែន?

ប៊ុនឡុង ៖ បាទ!ប៉ុនមិនដឹងនាមត្រកូលឈ្មោះអីទេ យើងអត់ដឹង ។

ដានី ៖ អ្ហូ!វ៉ែន មិនមែន វ៉ែនកូនប្រសារតាម៉ុកទេ?

ប៊ុនឡុង ៖ វ៉ែន ហ្នឹងហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ វ៉ែន វ៉ែន ហ្នឹង ។

ដានី ៖ អ្ហូ! អញ្ចឹង គាត់ស្លាប់យូរហើយ ។

ប៊ុនឡុង ៖ បាទ!

ដានី ៖ បើតាមខ្ញុំឮ តាមពត៌មានដូចថាឮតាម៉ុកគាត់បាញ់ចោលផងអី?

ប៊ុនឡុង ៖ អាហ្នឹងស្លាប់កាលពី៧០ ប្រឡោះអាដែងណៃ ប្រឡោះអា៧៨-៧៩ ដែលយើងរត់ហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ម៉ាអំឡុងហ្នឹង អាហ្នឹងគាត់នៅកងពលហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ កងពលទី២ហ្នឹងណាស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គាត់នៅជាប្រធានកងពល វ៉ែនហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែក្រោយដែលខ្ញុំផ្លាស់ចេញទៅស្វាយរៀងទៀតទៅ អាហ្នឹងវាកងពលផ្សេងទៀត ។

ដានី ៖ គាត់កងពលផ្សេងទៀតយ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ! ព្រោះខ្ញុំផ្លាស់ពីកងពលទី២ ទៅនៅស្វាយរៀងអាហ្នឹង ខ្ញុំចូលទៅខាងកងសេនាធិការ ។

ដានី ៖ អ្ហូ! ចូលទៅខាងកងសេនាធិការ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អាហ្នឹងដល់ពេលពូផ្លាស់ចេញពីកងពលទី២ម៉ោស្វាយរៀងហ្នឹង ចូលខាងកងពលសេនាធិការវិញ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អ្ហូ! គេហៅកងពលអីគេដែលហ្នឹង?

ប៊ុនឡុង ៖ បាទ! ហ្នឹងកងពលសេនាធិការប្រចាំ អាហ្នឹងបើយើងនិយាយទៅ កងពលហ្នឹងវាប្រចាំទូទាំងប្រទេស គេអាចចល័តបានទៅឯណាក៏បានដែរ ។

ដានី ៖ បាទ! អត់មានលេខទេ?

ប៊ុនឡុង ៈ មាន ។

ដានី ៈ លេខប៉ុន្មានទៅអាហ្នឹង?

ប៊ុនឡុង ៈ កងពល២២១ ។

ដានី ៈ កងពល២២១?

ប៊ុនឡុង ៈ បាទ!អញ្ចឹងមេកងពលនៅសព្វថ្ងៃនេះ ឯកឧត្តម អៀង ផាននេះ ។

ដានី ៈ អៀង ផានហ្នឹង?

ប៊ុនឡុង ៈ បាទ!

ដានី ៈ កងពល២២១?

ប៊ុនឡុង ៈ បាទ!

ដានី ៈ ឯកឧត្តម អៀង ផាន?

ប៊ុនឡុង ៈ បាទ!ប្រធានកងពល?

ដានី ៈ អៀង ផាន ឥឡូវគាត់ធ្វើអី?

ប៊ុនឡុង ៈ បាទ!អៀង ផាន ឥឡូវគាត់ខាងនេះ គាត់ខាងអាដែលភូមិភាគ អ៊េស!ខាងអាដែងអី ភូមិភាគ៥ហ្នឹងឯង ។

ដានី ៈ ខាងភូមិភាគ៥?

ប៊ុនឡុង ៈ បាទ!

ដានី ៈ ខាងបាត់ដំបងយើងនេះ?

ប៊ុនឡុង ៈ បាទ!ភូមិភាគបាត់ដំបងយើងហ្នឹង ។

ដានី ៈ ជាមួយ ឯកឧត្តម ប៊ុន សេងហ្នឹង?

ប៊ុនឡុង ៈ បាទ!ហ្នឹងហើយ ប៉ុន្តែគ្រាន់ថា គាត់រងអញ្ចឹងណាស់ គាត់ផ្កាយមួយហ្នឹង ។

ដានី ៈ អ្ហូ!បាទ ។

ប៊ុនឡុង ៈ ផ្កាយ១ឬ២ទេ ។

ដានី ៈ បាទ!អញ្ចឹងកាលហ្នឹងម៉ោផ្ទាស់ម៉ោ កងពលរបស់សេនាធិការ ២២១?

ប៊ុនឡុង ៈ បាទ!

ដានី ៈ កាលហ្នឹងផ្ទាស់ម៉ោ ពួយ៉ាងម៉េចទៅ យើងនៅជាយុវជនដដែល ឬយើងមានតួនាទីផ្សេង?

ប៊ុនឡុង ៈ បាទ!ខ្ញុំនៅជាយុវជនដដែលទេ ។

ដានី ៖ បាទ! ហើយយ៉ាងម៉េចទៅ ដល់ពេលកាលដែលយើងម៉ោខាងព្រំដែននៅខាងស្វាយរៀង ហើយយ៉ាងម៉េចមានការផ្លាស់ប្តូរស្ថានភាពអីយ៉ាងម៉េច ដូចថា?

ប៊ុនឡុង ៖ បាទ! ស្ថានភាពវាៗដូចតែនៅឯណោះដែរ ដូចតែយើងនៅនិរតីដែរ ព្រោះអាហ្នឹងមានអីផ្លាស់ពីហ្នឹងម៉ោ យើងថាមិនមែននេះណា៎ យើងម៉ោឡើងខាងផ្នែក សេនាធិការហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ខាងផ្នែកសេនាធិការវាត្រូវការណែ៎ការប្រយុទ្ធដូចតែគ្នា កន្លែងណាដែលគេធ្វើមិនកើត គឺមានកងហ្នឹងដាក់ ។

ដានី ៖ បាទ! មួយទៀតខ្ញុំឆ្ងល់ថា ដល់ពេលយើងវៃជាមួយយួន យើងនៅតាមព្រំដែន នៅខាងភ្នំឪន ក៏យើងព្រំដែនជាមួយយួនដែរ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ មិនយើងវៃដែរ ម៉េចបានយើងដកចេញពីហ្នឹងម៉ោនៅស្វាយរៀងវិញ?

ប៊ុនឡុង ៖ អានេះខ្ញុំអត់ដឹងដែរ ព្រោះឧទាហរណ៍ថាខ្ញុំនៅសមរភូមិ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងបានគេរៀបចំថា ឥឡូវមានឈ្មោះ ខ្ញុំត្រូវទៅនៅស្វាយរៀង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងមូលហេតុអីៗ ខ្ញុំអត់ដឹងដូចគ្នា ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ គេអត់មានប្រាប់ថា អ្ហូ! ឥឡូវអ៊ីឈ្មោះលោកពូត្រូវផ្លាស់ទៅនេះដោយសារមូលហេតុដូចថានៅនេះអត់សូវមាន ស្ថានភាពវាធូរស្រាល ទៅនោះមានការតឹងតែង ត្រូវតែដកអីទៅនោះ ហើយពូមានដឹងថាម៉េចៗទេ?

ប៊ុនឡុង ៖ អត់! មានតែគេទៅតាមម៉ោ ម៉ោដល់ឥឡូវគ្រាន់តែប្រាប់តែប៉ុណ្ណោះ ប្អូនឯងត្រូវទៅស្វាយរៀង ។

ដានី ៖ កាលហ្នឹងពូអត់មានប្រកែកទេ?

ប៊ុនឡុង : បាទ!ចុះធ្វើម៉េចកងទ័ពទៅហើយ គេគ្រប់គ្នា ដូចថាគេទៅបានដូចតែគ្នា ហើយយើងមួយយើងអត់មានប្រកែកទេ ហើយអញ្ចឹងយើងជំនាន់ហ្នឹង អ្នកណាមានតួនាទីទៅណាទៅហ្នឹង ។

ដានី : បាទ!

ប៊ុនឡុង : បាទ!អ្នកណាមានមុខតួនាទីទៅខាងណា ទៅខាងហ្នឹង ។

ដានី : ចុះកាលហ្នឹងពូទៅស្វាយរៀងនៅម្តុំណាទៅនៅស្វាយរៀង?

ប៊ុនឡុង : បាទ!ទៅដល់ទៅស្វាយរៀង គិតទៅអត់មានទៅនៅឯណាឆ្ងាយទេ ព្រោះកន្លែងសេនាធិការដាក់នៅប្រចាំនៅហ្នឹងក្រុងស្វាយរៀងហ្នឹងម៉ង ។

ដានី : នៅក្រុងស្វាយរៀងម៉ង?

ប៊ុនឡុង : បាទ!

ដានី : អញ្ចឹងពូនៅក្នុងទីក្រុងទេ អត់បានទៅព្រំដែនទេអញ្ចឹង?

ប៊ុនឡុង : អត្តេះ!កម្លាំងឈរនៅក្នុងស្វាយរៀង ។

ដានី : បាទ!

ប៊ុនឡុង : តែប្រសិនបើករណិយើងត្រូវវ៉ៃ កម្លាំងហ្នឹងចេញវ៉ៃ ។

ដានី : បាទ!

ប៊ុនឡុង : បាទ!ព្រោះមា៉កងពលហ្នឹងនៅ ប្រចាំការហ្នឹង ។

ដានី : បាទ!

ប៊ុនឡុង : បាទ!មានការដូចខ្ញុំនិយាយថា ខ្នាំងបុកអីម៉ោប្រឡោះណាខ្លាំងអីអញ្ចឹងទៅ ។

ដានី : បាទ!

ប៊ុនឡុង : បាទ!កន្លែងហ្នឹងដូចថាមិនអាចហៅជំនួយ គឺកម្លាំងហ្នឹងហើយដែលទៅជួយ ។

ដានី : បាទ!ចុះពូកាលហ្នឹងមានស្គាល់កងពល៧០៣ទេ?

ប៊ុនឡុង : បាទ!៧០៣កើតមុន២២១ ។

ដានី : បាទ!កើតមុនកងពល២២១ ។

ប៊ុនឡុង : បាទ!អញ្ចឹង២២១នេះកើតក្រោយទេ ។

ដានី : បាទ!

ប៊ុនឡុង : ៧០៣ប្រចាំតាំងពីនៅភ្នំពេញ ។

ដានី : បាទ!តាំងពី៧៥នោះ?

ប៊ុនឡុង ៖ បាទ!អញ្ចឹង២២១ នេះកើត៧៨ដែលទៅនេះហ្នឹងទេ ជិតចូល៧៩ហ្នឹងហើយ ។

ដានី ៖ អូ!ប៉ុន្តែដល់ពេលយើងទៅស្វាយរៀងទៅជួបគ្នាដែរ?

ប៊ុនឡុង ៖ ជួបគ្នាដែរ ។

ដានី ៖ ជួបគ្នា?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ទៅជួបគ្នា ប៉ុន្តែកងពលរបស់លោកពូប្រចាំនៅក្រុងម៉ង យើងវៃយើងជួយវៃតែពេលណាមានការដូចថាសភាពការណ៍តឹងតែងខ្លាំង បានយើងទៅ?

ប៊ុនឡុង ៖ បាទ!កន្លែងណាស្អុកស្អាញហ្នឹង គេដាក់ឲ្យហើយ ។

ដានី ៖ គេដាក់ទៅ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ យ៉ាងម៉េចដែរកាលហ្នឹង កាលពីយើង សមរភូមិកាលហ្នឹងយើងដូចថាតឹងតែងយ៉ាងម៉េចទៅ?

ប៊ុនឡុង ៖ តឹងតែងអញ្ចឹង បានថាវាអត់អីទេ ធម្មតាតែវៃ ធម្មតាធ្វើសង្គ្រាមវាមានការត្រូវ របួសខ្ញុំចាប់ត្រូវរបួសតាំងពីហ្នឹងទៅ ចាប់ត្រូវរបួសតាំងពីយើងនៅភ្នំឱិននេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ភ្នំឱិននេះខ្ញុំត្រូវ២ដង ៣ដង ។

ដានី ៖ ត្រូវកន្លែងណាខ្លះទៅ ?

ប៊ុនឡុង ៖ បាទ!អានេះទៅត្រូវនៅស្វាយរៀង ។

ដានី ៖ អូ!អានេះត្រូវ?

ប៊ុនឡុង ៖ បាទ!ខ្ញុំកងស៊ើបការ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដល់ពេលស៊ើបហើយ អីហើយអញ្ចឹងទៅ ត្រូវអូសកម្លាំងយកទៅវៃ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងគេទុកឲ្យយើងធ្វើកម្លាំងទី៣ ដល់ធ្វើកម្លាំងទី៣មកជួយធ្វើអន្តរាគមន៍ ដល់អញ្ចឹងទៅចុះឡើងៗ គេថាឲ្យមេគេទៅ គេថាអត់ទេ កម្លាំងទី៣ហ្នឹង មិនអាចទុកឲ្យបានទេ ទុកយកម៉ោដាក់នៅកម្លាំងទី១ព្រោះអ្នកហ្នឹងស៊ើបហើយ ខ្ញុំអត់ទាន់បានវៃផងទេ គ្រាន់តែដើរទៅថា វាធាក់មីន ។

ដានី ៖ ទាក់មីនរបស់យួន?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដើរទៅទាក់មីន?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ត្រូវអំបែងៗ?

ប៊ុនឡុង ៖ បាទ!ត្រូវអំបែង ត្រូវអីហ្នឹង ។

ដានី ៖ ឆ្នាំណាដែលពូទៅហ្នឹង?

ប៊ុនឡុង ៖ ត្រូវហ្នឹងឆ្នាំ៧៨ ។

ដានី ៖ ឆ្នាំ៧៨ ខែប៉ុន្មានទៅ?

ប៊ុនឡុង ៖ អាចខែ៨-៩ហ្នឹង ព្រោះ៧៨ ខែប៉ុន្មានដែលទឹកលិចហ្នឹង តាំងពីអ្នកលឿងនេះទៅលិចចូលក្រុងស្វាយរៀងហ្នឹង ។

ដានី ៖ ខ្ញុំអត់ដឹង ។

ប៊ុនឡុង ៖ បាទ!ក្មួយឯងកើតទាន់ដែរឬអត់ទេ?

ដានី ៖ អត់ទាន់!កើតទាន់ ប៉ុន្តែតូចអត់ទាន់ដឹង ។

ប៊ុនឡុង ៖ អ្ហ៎!អញ្ចឹងអេស! ។

ដានី ៖ បាទ!ដល់អញ្ចឹងដល់ពេលពូត្រូវ របួសហ្នឹងយើងម៉ោសម្រាកព្យាបាលនៅណាទៅ?

ប៊ុនឡុង ៖ បាទ!នៅភ្នំពេញ ។

ដានី ៖ គេបញ្ជូនពីនោះម៉ោ អូរដឹកពីនោះម៉ោ?

ប៊ុនឡុង ៖ បាទ!ដឹកពីនោះម៉ោ ដាក់កប៉ាល់ម៉ោ ម៉ោដល់ភ្នំពេញ សម្រាកនៅពេទ្យភ្នំពេញ ។

ដានី ៖ ពេទ្យមួយណា?

ប៊ុនឡុង ៖ បាទ!ពីមុនគេហៅពេទ្យ៦មករា ។

ដានី ៖ ពេទ្យជិតវត្តភ្នំ?

ប៊ុនឡុង ៖ បាទ!ហ្នឹងហើយ ។

ដានី ៖ គេតុមាលាឥឡូវ សម្រាកយូរដែរ?

ប៊ុនឡុង ៖ មួយខែជាង ។

ដានី ៖ មួយខែជាងហើយ ពូត្រឡប់ទៅសមរភូមិវិញ ឬក៏យ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ!ទៅវិញ ។

ដានី ៖ ទៅវិញ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចុះកាលពូត្រូវរបួសនៅភ្នំឱិន ពូត្រូវរបួសកន្លែងណាខ្លះទៅ?

ប៊ុនឡុង ៖ បាទ!នៅភ្នំឱិន ខ្ញុំត្រូវក្បាល ត្រូវអីហ្នឹង ។

ដានី ៖ ត្រូវតិចៗទេ?

ប៊ុនឡុង ៖ បាទ!ម៉ាល្មមដែលទេ ត្រូវកៀនស្លឹងត្រចៀកអីនេះ ។

ដានី ៖ ត្រូវអីគេ មូលហេតុអី?

ប៊ុនឡុង ៖ បាទ!អាហ្នឹងពេលឡើងវៃ ហ្នឹងត្រូវគ្រាប់ផ្លោង ។

ដានី ៖ បាទៗ!៦០មីលីម៉ែត្រ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អាហ្នឹងត្រូវអំបែងវា?

ប៊ុនឡុង ៖ បាទ!ហើយវៃមួយដងទៀតនោះ ផុះមីនដែរ ត្រូវនេះ ក្រោយនេះ ។

ដានី ៖ អាហ្នឹងកាលនៅភ្នំឱិន ឆ្នាំណាហ្នឹង?

ប៊ុនឡុង ៖ អាហ្នឹងឆ្នាំយើងវៃជាមួយយួនដែលហ្នឹង ៧៨ដែលហ្នឹង ។

ដានី ៖ ប៉ុន្តែ មិនទាន់ដួលរលំម៉ោស្វាយរៀង ?

ប៊ុនឡុង ៖ មិនទាន់ដួលរលំម៉ោស្វាយរៀងទេ ។

ដានី ៖ នៅដើមឆ្នាំ៧៨ ដល់ពេលត្រូវ?

ប៊ុនឡុង ៖ ហើយមួយដងទៀត ត្រូវរបួសខាងបោះដៃផុតក្រោយនេះ អានេះត្រូវវៃចូលស្រុកយួនមុនម៉ោស្វាយរៀងហ្នឹងដែល ។

ដានី ៖ វៃចូលដល់ណាដែរលោកពូ?

ប៊ុនឡុង ៖ បាទ!ចូលទៅហួសផ្សារក្របៅ ហួសភ្នំតូច ភ្នំធំ ភ្នំក្តែងស្រុកយួនហ្នឹង ។

ដានី ៖ អូ!

ប៊ុនឡុង ៖ ទៅឃើញអញ្ចឹងបានថា យើងនៅក្នុងស្រុកយួន គឺនៅមានវត្តខ្មែរយើង មានរូបព្រះពុទ្ធសាសនាខ្មែរយើងទាំងអស់ ។

ដានី ៖ អូ!កាលពូវៃចូលទៅហ្នឹង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ វៃចូលទៅបានជ្រៅទេ?

ប៊ុនឡុង : បានជ្រៅដែលហ្នឹង ។

ដានី : ប្រហែលជាប៉ុន្មានគីឡូ?

ប៊ុនឡុង : បាទ!ទៅម៉ាដួរហ្នឹង ប្រហែលជា១០គីឡូហ្នឹង ចូលទៅនិយាយទៅ យួនមានតែតាមទីផ្សារទេ ។

ដានី : បាទ!

ប៊ុនឡុង : ដែលតាមទីជនបទវិញ សុទ្ធតែខ្មែរយើងទេ ខ្មែរកម្ពុជាក្រោម ។

ដានី : ម៉េចទៅ ដល់ពេលយើងចូលទៅ ជួបអញ្ចឹងទៅយ៉ាងម៉េចទៅ?

ប៊ុនឡុង : បាទ!អញ្ចឹងបងប្អូនកម្ពុជាក្រោមរាក់ទាក់របូតទៅដល់យើងអូសទាញ អូសទាញជិនាន់នោះអូសទាញបានម៉ោជួយតស៊ូ ។

ដានី : ម៉ោខាងយើងនេះ?

ប៊ុនឡុង : បាទ!មានម្ហូប មានទាំងកងពល ។

ដានី : អ្ហូ!ម៉ោដល់ ម៉ោនៅតាកែវហ្នឹង ?

ប៊ុនឡុង : បាទ!ម៉ោនៅតាមព្រំដែន ម៉ាដួរភ្នំឌិន ម៉ាដួរនេះហ្នឹងទៅយើងកោះអណ្តែតហ្នឹងទៅម៉ាដួរហ្នឹង ។

ដានី : បាទ!ឆ្នាំណាដែលពូចូលទៅ ហើយបានយើងអូសទាញបានពួកគាត់ហ្នឹងម៉ោ?

ប៊ុនឡុង : អាហ្នឹងឆ្នាំ៧/៨ហ្នឹងឯង ។

ដានី : ៧/៨ហ្នឹងដែរ?

ប៊ុនឡុង : បាទៗ!

ដានី : តែកាលយើងចូលទៅហ្នឹង បើយួនម៉ងគឺនៅតែតាមទីផ្សារទេ?

ប៊ុនឡុង : បាទ!នៅតាមទីផ្សារ នៅតាមទីតាំងរបស់វាអញ្ចឹងទៅ ។

ដានី : បាទ!អ្នកនៅតាមភូមិសុទ្ធតែខ្មែរយើង បងប្អូនកម្ពុជាក្រោម?

ប៊ុនឡុង : បាទ!ខ្មែរ ភាគច្រើនសុទ្ធតែខ្មែរយើង ព្រោះខ្មែរ ចុះទឹកដីយើងនៅហ្នឹងច្រើនដែល នោះអញ្ចឹងវាអត់ខុសអីនឹងខេត្តសុរិនទេ ។

ដានី : បាទ!ខេត្តណា?

ប៊ុនឡុង : ខេត្តសុរិនថៃហ្នឹង ចុះមិនឃើញសុទ្ធតែខ្មែរទេ ។

ដានី : អ្ហូ!ខ្ញុំអត់ដែលទៅទេ បាទ!អញ្ចឹងពេលយើងចូលទៅ តើយើងចាប់បាន ចាប់អីយកម៉ោដែរ ពួកយួន?

ប៊ុនឡុង ៖ បាទ!កន្លងទៅ ការប្រយុទ្ធមិនដែលឃើញចាប់បានផងពួកយួន ក្រែងលរអង្គភាព ផ្សេងៗ បើអង្គភាពខ្ញុំចាប់អត់បានទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ហើយដូចជា ខ្មែរកម្ពុជាក្រោមដែលនៅទឹកដីយួនហ្នឹង គឺគាត់ស្ម័គ្រចិត្តម៉ោធ្វើជាកងទ័ព ជាមួយយើង ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ អាហ្នឹងពូបាននិយាយជាមួយគាត់ ហើយគាត់បានមកតាមម៉ងឬយ៉ាងម៉េច ?

ប៊ុនឡុង ៖ បាទ!អានេះខ្ញុំមិនបាននិយាយជាមួយគាត់ទេ តែការសួរការអីដែលពេលគាត់រៀបចំមានអង្គភាពរបស់គាត់ទៅ គាត់ថាគាត់ជាខ្មែរ អញ្ចឹងមិនដឹងជាមានជនាន់ណាអីជនាន់ ណាដែលទឹកដីខ្មែរបាត់បង់ គឺគាត់ចង់បាន ។

ដានី ៖ ចង់បានម៉ោវិញ?

ប៊ុនឡុង ៖ បាទ!អញ្ចឹងគាត់រួមជាមួយយើង ។

ដានី ៖ បាទ!ពេលដែលយើងវ៉ៃចូលទៅ កាលហ្នឹងទាហានយួនអីគេមានវ៉ៃអីៗយើងឬអត់ បើយើងចូលដល់ទឹកដីគៀកយួនហើយ ។

ប៊ុនឡុង ៖ រឿងនេះវាមិនអាចថា យើងចូលហើយគេមិនអាចនេះទេ តែដើមកំណើតមុនដំបូង គឺយួនហ្នឹងហើយ ដែលចូលយើងមុន ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ដែលម៉ោបំផ្លិចបំផ្លាញភូមិឋាន ជាដំណាំដាំដុះ ដូចជាដូង ដូចជាស្លឹ គឺវាកាប់ដើមកាប់ ស្លឹស៊ី ផ្ទះសំបែងប្រជាពលរដ្ឋគឺវាដុតខ្ទិចខ្ទី ។

ដានី ៖ នៅណា?

ប៊ុនឡុង ៖ អញ្ចឹង!បាទខាងលិចភ្នំខ្និនម៉ោម៉ាដូរស្លឹគេ ខ្ញុំភ្លេចអស់ហើយ ម៉ាដូរហ្នឹង ឲ្យតែវាចូលម៉ោដល់គឺវាដុតផ្ទះ បាទ!បំផ្លាញដំណាំដាំដុះ ដំណាំយុទ្ធសាស្ត្រ ដូចជាដូង ដូចៗអីអញ្ចឹងទៅណាស់ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងក្រោយពីយើងរត់ដល់ពេលយើងរៀបចំកម្លាំងបានវិញគឺ យើងទប់ហើយយើងវៀតទៅវិញ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងការវាយតទៅវិញហ្នឹង គឺធម្មតាយើងនៅតាមព្រំដែន អញ្ចឹងគេចេះតែលួចមកវ៉ៃ អញ្ចឹងគេលួចម៉ោវ៉ៃ អញ្ចឹងយើងក៏ចូលឆ្នកវ៉ៃដូចតែគ្នា ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ វាអញ្ចឹង!វាទៅវិញទៅម៉ោអញ្ចឹង ។

ដានី ៖ បាទ!បើយើងចូលទៅ យើងមាន ដូចយួនចូលម៉ោយើង យើងបំផ្លាញផ្ទះ ដូងអីដំណាំរបស់គេដែរ?

ប៊ុនឡុង ៖ យើងគិតថាបើសិនកាលនោះវានេះដែរណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បើសិនជាគិតថា បើយើងយកទឹកដីហ្នឹងបានវិញ អញ្ចឹងជាទឹកដីខ្មែរដំណាំយើងអត់បំផ្លាញអីទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!យើងទុកឲ្យនៅហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!យើងបំផ្លាញតែ កន្លែងទីតាំង ។

ដានី ៖ កន្លែងទីតាំង កន្លែងកងទ័ព?

ប៊ុនឡុង ៖ បាទ!ហ្នឹង ។

ដានី ៖ ព្រោះខ្ញុំធ្លាប់អានឯកសារៗកាលហ្នឹង កាលហ្នឹងពីឆ្នាំ៧៧ជាងហ្នឹង ខាងកងទ័ព កងទ័ពខ្មែរក្រហម បានចូលទៅដល់ទីតាំងហ្នឹង ចូលដល់ស្រុកយួនហើយមាន ចូលក្នុងភូមិយើងបានដុតភូមិ យើងបាន ដូចមានសម្លាប់ច្រើនអីអញ្ចឹង អាហ្នឹងតាមខ្ញុំអានឯកសារអានឯកសារទៅឃើញមានគេ និយាយអញ្ចឹង អាហ្នឹងមែនដែរក៏យ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ!អានេះវាដូចខ្ញុំបានជំរាបខាងដើមអញ្ចឹង អង្គភាពផ្សេងៗមិនដឹងគេយ៉ាងម៉េច ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អង្គភាពខ្ញុំផ្សេង អញ្ចឹងអាហ្នឹងខ្ញុំនិយាយអត់កើតដែរ ។

ដានី ៖ បាទ!ខ្ញុំអត់ដឹងខ្ញុំនិយាយអត់កើតទេ ។

ប៊ុនឡុង ៖ បាទ! អញ្ចឹងសម្រាប់អង្គភាពខ្ញុំគឺ មិនមានអីដល់ថ្នាក់អញ្ចឹងទេ ទល់មុខ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!តែបើយួនចូលម៉ោ ដូចខ្ញុំនិយាយខាងដើមអញ្ចឹង គឺគាត់ដុត គាត់បំផ្លាញភូមិ សូម្បីតែជង្រុកស្រូវក៏គាត់ដុតដែរ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងអាជិនទាន់ហ្នឹងហើយ ដែលប្រជាពលរដ្ឋដែលនៅតាមតំបន់ព្រំដែន គាត់ខ្វះខាត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាដែងណែ៎ ការហូបចុកដែលពេលចូលម៉ោហ្នឹងហើយ គេដុតផ្ទះ ដុតជង្រុកស្រូវ ដុតអីទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ កាលហ្នឹងដូចថាកងទ័ពអី មានហូបចុកគ្រប់គ្រាន់ដែរ?

ប៊ុនឡុង ៖ បាទ!ការវ៉ៃគ្នា កងទ័ពការហូបចុកគឺវាមិនខ្វះខាតអីទេ ។

ដានី ៖ អត់ខ្វះខាតអីទេ?

ប៊ុនឡុង ៖ បាទ!ព្រោះខ្ញុំហូបបាយជាប់រហូត ។

ដានី ៖ ហូបបាយរហូត?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចុះម្ហូប?

ប៊ុនឡុង ៖ ម្ហូប អាហ្នឹងកាលៈទេសៈតាមអញ្ចេះ ការឧបត្ថម្ភគាំទ្រពីខាងក្រោយអី នៅមានជាគោ មានជាជ្រូកអីអញ្ចឹងទៅ តែបើនៅតាមជួរខ្សែត្រៀម យើងនៅបឹង យើងអត់ខ្វះទេ ត្រី ។

ដានី ៖ អ្ហូ!សំបូរ ។

ប៊ុនឡុង ៖ បាទ!សំបូរត្រី ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!យើងដាំ ឲ្យតែគេយកបាយទៅ ម្ហូបគឺយើងមានត្រីត្រៀមទុក យប់ឡើងយើងឡើងចេញធ្វើការតាមព្រំដែនម៉ោវិញម៉ោ យើងចាប់ត្រីចាប់អីម៉ោ ហើយបងប្អូនអ្នកវែកបាយពីក្រោយទៅ គេបានបើកសាច់គោ បានបើកសាច់ជ្រូកឲ្យគេធ្វើម្ហូបទៅ ឲ្យទៅ ។

ដានី ៖ បាទ!អញ្ចឹងយើងមិនអត់ទេ?

ប៊ុនឡុង ៖ បាទ!យើងមិនអត់ទេ កងទ័ព ។

ដានី ៖ កងទ័ពបាយប៉ុន្មាន ២ពេលឬ៣ពេល?

ប៊ុនឡុង ៖ បាទ! បាយនេះគឺគេតម្រូវរែកទៅឲ្យហូបល្ងាច ហូបព្រឹក ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ល្ងាចឡើងបានគេរែកឲ្យហូបទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែយើងហូបប៉ុន្មានពេល ស្រាចតែយើងទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ! ព្រោះយើងកាលជំនាន់នោះយើងប្រើស្លុកប៉ុនៗនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ! ម្នាក់២ស្លុកអញ្ចឹងទៅ ម៉ាស្លុកសម្រាប់ល្ងាចហ្នឹង ម៉ាស្លុកទុកស្អែកព្រឹកឡើង អញ្ចឹងទៅ ។

ដានី ៖ បាទ! ចុះកាលជំនាន់ហ្នឹង ពូបានមកលេងផ្ទះទេ មកលេងឪពុកម្ដាយ មកលេងបង ប្អូន?

ប៊ុនឡុង ៖ បាទ! ជំនាន់នៅជាមួយយួនហ្នឹងអត់បានម៉ោទេ ។

ដានី ៖ អត់បាន?

ប៊ុនឡុង ៖ បាទ! ព្រោះហ្នឹងកំពុងតែជាប់ដៃ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ហើយជាប់ដៃហើយ ដល់អញ្ចឹងទៅវាមានការផ្លាស់ប្ដូរ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ផ្លាស់ប្ដូរពីអង្គភាពមួយដូចខ្ញុំប្រាប់អញ្ចឹង ពីភូមិភាគទៅសេនាធិការ ទៅខេត្តផ្សេង ទៀត ។

ដានី ៖ អ្ហូ! បាទ ។

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចុះកាលពូនៅខាងភ្នំឱិន នៅខាងកងទ័ពភូមិភាគ គាម៉ុកគាត់ខស្សាហ៍ទៅលេង ទៅសួរសុខឬក៏ទៅលើកទឹកចិត្តអីដែរ?

ប៊ុនឡុង ៖ បាទ! ជំនាន់នោះ ខាងគាត់ជាមេធំ គាត់ជាមេភូមិភាគ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងគាត់មិនអាចចុះផ្ទាល់ទៅដល់ខ្សែត្រៀមទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ! យ៉ាងច្រើនគាត់ចុះមកដល់កន្លែងវរៈធំ ឬក៏កន្លែងកងពលទេ ។

ដានី ៖ បាទ!ពូអត់ដែលជួបគាត់ទេ?

ប៊ុនឡុង ៖ មិនដែលជួបទេ បាទ!ជួបពេលណាដែលគាត់ម៉ោកន្លែងនេះអញ្ចឹងយើងបានពេលម៉ោក្រោយអីអញ្ចឹងទៅ ហើយក៏យើងបានសម្រាកពេទ្យអីអញ្ចឹង គាត់ទៅសួរសុខទុក្ខបងប្អូនសម្រាកពេទ្យហ្នឹង កង១ទ័ពហ្នឹង ។

ដានី ៖ អញ្ចឹងគាត់ធ្លាប់ទៅសួរសុខទុក្ខលោកពូដែរ?

ប៊ុនឡុង ៖ បាទ!និយាយទៅគាត់បានជួបគាត់មានតែពេលដែលយើងសម្រាកនៅពេទ្យ គាត់ចូលទៅមន្ទីរពេទ្យអញ្ចឹងទៅ យើងបានជួបគាត់ ។

ដានី ៖ នៅណាហ្នឹង ពេទ្យនៅណាពេទ្យ?

ប៊ុនឡុង ៖ បាទ!ពេទ្យហ្នឹងវាច្រើនកន្លែង របួសល្មម១អញ្ចឹងទៅ យើងមានពេទ្យមួយនៅម៉ាត់ព្រៃសណ្តែក ។

ដានី ៖ ព្រៃសណ្តែក អ៊ូ!ព្រៃសណ្តែកជិតតាកែវ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ហួសពីតាកែវទៅបន្តិចហ្នឹង?

ប៊ុនឡុង ៖ បាទ!ហើយពេទ្យមួយទៀតម៉ោតាកែវ ពេទ្យម៉ាកន្លែងទៀតពេទ្យដើមច្របក់ផ្លូវបំបែកអង្គតាសោមនេះ ។

ដានី ៖ អ៊ូ!បាទពូធ្លាប់សម្រាកទាំង៣ពេទ្យហ្នឹង?

ប៊ុនឡុង ៖ អញ្ចឹងពេទ្យធំគឺភ្នំពេញ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងពេទ្យ ពេទ្យប៉ុន្មានកន្លែងហ្នឹងគឺខ្ញុំសម្រាកទាំងប៉ុណ្ណឹងកន្លែងហ្នឹងឯង ដើមចំបក់ក៏ខ្ញុំសម្រាក តាកែវក៏ខ្ញុំសម្រាកបាទ!ព្រៃសណ្តែកក៏ខ្ញុំសម្រាក ។

ដានី ៖ ពេលត្រូវរបួស?

ប៊ុនឡុង ៖ បាទ!ត្រូវរបួសតិចទៅ ទៅព្រៃសណ្តែក ត្រូវរបួសរាងធ្ងន់ទៅ តាកែវ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហ៎!អារាងគ្រាន់បើនេះហើយគេបញ្ជូនទៅ អាកន្លែងម៉ោដើមចំបក់ជិតអង្គតាសោមនេះម៉ោ ។

ដានី ៖ អ៊ូ!ចុះម៉ោដល់សេនាធិការ ដល់ពេលម៉ោកងពល២២១ខាងសេនាធិការនេះ១ សេនាធិការនេះលែងក្រោមតាម៉ុកទៀតហើយ?

ប៊ុនឡុង ៖ បាទ!អាហ្នឹងខ្ញុំគ្រាន់តែដឹងថា ខ្ញុំនៅអគ្គភាពសេនាធិការកងពល២២១ ក្រៅពីហ្នឹងទៀតអ្នកណាដែលគ្រប់គ្រងពីលើកងពលហ្នឹងទៀតខ្ញុំអត់ដឹងដែរ ។

ដានី ៖ អត់ដឹងទេ?

ប៊ុនឡុង ៖ បាទ!អត់ដឹងទេ ។

ដានី ៖ ព្រោះច្រើនតាមខ្ញុំធ្លាប់ជួបពូមីង គាត់ថាច្រើនតែ គាត់ម៉ោសួរសុខទុក្ខ ម៉ោលើកទឹកចិត្តអីអញ្ចឹង ។

ប៊ុនឡុង ៖ បាទ!

ដានី ៖ បាទ!ខាងសេនាធិការបើតាមខ្ញុំដឹង សុន សេន គាត់ខាងអគ្គសេនាធិការ គាត់ចុះម៉ោខាងសមរភូមិ គាត់ម៉ោសួរសុខទុក្ខអីអញ្ចឹង?

ប៊ុនឡុង ៖ បាទ!តែជំនាន់នោះយើងអត់ស្គាល់គាត់ ។

ដានី ៖ អត់ស្គាល់គាត់?

ប៊ុនឡុង ៖ ជួនកាលក៏គាត់ទៅ យើងម៉េចដឹងថាគាត់ទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ព្រោះដូចតាម៉ុក តាម៉ុកអ្នកស្គាល់ ស្គាល់ អ្នកអត់ស្គាល់ដើរទល់មុខគាត់ក៏យើងអត់ស្គាល់ ព្រោះគាត់ជំនាន់ធ្វើសង្គ្រាមហ្នឹង គាត់ស្លៀកពាក់ជាស៊ីវិលធម្មតា ធ្វើដូចអាដែងណែកសិករអញ្ចឹង ។

ដានី ៖ ធម្មតា?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អត់មានទីនុយអីទេ?

ប៊ុនឡុង ៖ អត់មានទីនុយ អត់មានអីនេះឲ្យហំហានអីណានេះទេ បាទ!អញ្ចឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងបានថាខ្ញុំអត់ទេ គ្រាន់តែថាដឹងឯកឧត្តម អៀង ផាន រាល់ថ្ងៃនេះ គាត់ជាប្រធានកងពលតែប៉ុណ្ណឹងឯង ។

ដានី ៖ បាទ!មានដែលរាប់អានគាត់អីដល់ឥឡូវទេ?

ប៊ុនឡុង ៖ អត់!

ដានី ៖ អត់ដែលរាប់អានទេ?

ប៊ុនឡុង ៖ គាត់ក៏គាត់ថាក្មេចមុខខ្ញុំ ខ្ញុំនៅចំណាំគាត់បានប៉ុនតែថា យើងជាប្រជាពលរដ្ឋ ហើយគេ គេជាដូចថា ជាមន្ត្រីរាជការ ជាកងប្រដាប់អាវុធ យើងអត់មានអាដែងណែ៎ អាហ្នឹង យើងមិនថានេះអីគេ ដូចថាវាដូចគ្មានការងារអីទៅសួរគាត់ផង ពេលគាត់ម៉ោគាត់ជិះ ឡាន ពេលគាត់ចូលវិញ <u>ឧទាហរណ៍</u> ថាគាត់ចល័តតាមបន្ទាយអញ្ចឹង គាត់ចូលបន្ទាយ គាត់ទៅ គាត់មានទៅបាននេះគ្នាឯណា មានតែដើរចុះសួរ មើលតែកងទ័ពគាត់ហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចុះពូដល់ពេលអើ ឆ្នាំ៧៩ដល់ពេលយើង យួនចូលម៉ោម៉េចទៀតទៅ?

ប៊ុនឡុង ៖ បាទ!អាហ្នឹងគ្រប់អង្គភាពទាំងអស់ គឺរត់ដូចតែគ្នាហ្នឹង ។

ដានី ៖ បាទ!អញ្ចឹងពេលពូ ដែលពូម៉ោសម្រាកពេទ្យ នៅពេទ្យ៦មករាហើយពូត្រឡប់ទៅអង្គភាពវិញនៅស្វាយរៀងដដែល?

ប៊ុនឡុង ៖ បាទ!

ដានី ៖ នៅស្វាយរៀងរហូតដល់បែកបណ្ដួយ?

ប៊ុនឡុង ៖ អាហ្នឹងខ្ញុំចូលទៅស្រុកយួនមួយសារទៀត ។

ដានី ៖ ចូលទៅដល់ណាហ្នឹង?

ប៊ុនឡុង ៖ បាទ!អាហ្នឹងគេហៅថាដីខ្លាញ់ ។

ដានី ៖ ដីខ្លាញ់?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដីក្រហម ឬដីខ្លាញ់?

ប៊ុនឡុង ៖ អាហ្នឹងពីដើមគេហៅថាដីខ្លាញ់ ប៉ុនមិនដឹងថាឥឡូវគេហៅដីអី ចូលប្រឡោះត្រឡោក បែកអីទៅហ្នឹងឯង ចូលទៅហ្នឹងទៅដល់ថ្នល់ជាតិយួននោះ ឆ្លងកាត់ឡើងប៉ុន្មាននេះនោះ ណា៎ ចូលទៅក្នុងឧទាហរណ៍ថាព្រំដែនអញ្ចឹងទៅ វាចាក់ថ្នល់ក្រហម ខ្ញុំឆ្លងថ្នល់ក្រហម អញ្ចឹងទៅ គាត់ទៅ គាត់ស៊ីង២-៣ទៀតបាន បានទៅដល់នេះអ៊ុះ! ។

ដានី ៖ អ៊ូ!កាលហ្នឹងពូ កងសើបការ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ កាលហ្នឹងចូលមានគ្នាប៉ុន្មាននាក់ដែរ?

ប៊ុនឡុង ៖ ចូលទៅហ្នឹង កាលហ្នឹងគ្នាអត់ច្រើនទេ គ្នាប្រហែល១០០នាក់ជាងទេ ។

ដានី ៖ ១០០នាក់?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អ្ហូ!យើងចូលទៅហ្នឹង របៀបម៉េចទៅ ពេលថ្ងៃឬពេលយប់?

ប៊ុនឡុង ៖ បាទ!ព្រោះទៅម៉ាដួរហ្នឹងព្រៃ។

ដានី ៖ ព្រៃ?

ប៊ុនឡុង ៖ បាទ!យើងអានព្រៃ។

ដានី ៖ យើងម៉េចដឹងភូមិសាស្ត្រស្រុកគេ បើយើងអត់ដឹង?

ប៊ុនឡុង ៖ អានេះវាមាន អ្នកចូលមុន ដល់អញ្ចឹងទៅ គេចូលមុនគេដឹងភូមិសាស្ត្រ ដឹងទៅបានគេអូសយើងតាមក្រោយទៀត។

ដានី ៖ អ្ហូ!ទៅយូរទេ ទៅទាំងយប់ទាំងថ្ងៃឬក៏យើងទៅតែពេលយប់?

ប៊ុនឡុង ៖ បាទ!អាហ្នឹងទៅ ទៅតម្រាំមទៅដល់នេះទៅទាំងយប់ទាំងថ្ងៃហ្នឹងឯង ដើរទាំងយប់ដើរទាំងថ្ងៃហ្នឹង ទៅប៉ះស៊ីងឆ្លងស៊ីងទៅ ។

ដានី ៖ ចុះអត់ប៉ះកងទ័ពយួនទេ?

ប៊ុនឡុង ៖ អត់!វាមានអាកន្លែងប្រហោង។

ដានី ៖ យើងចូលទៅធ្វើអីទៅអញ្ចឹង?

ប៊ុនឡុង ៖ បាទ!អាហ្នឹងយើងចូលទៅស៊ើបការ ចូលទៅនេះហ្នឹងដែរណា៎ ព្រោះអ៊ីធម្មតាចូលទៅវាមានគោលបំណងរឿងគេវ៉ៃយើង យើងមិនវ៉ៃគេ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គេចូលដូចតែគ្នាហ្នឹង អញ្ចឹងយើងយើងចូលទៅ រត់ប៉ះទៅដល់ណា ប៉ះត្រង់ណាវ៉ៃត្រង់ហ្នឹងដូចតែគ្នា។

ដានី ៖ បាទ!ចូលទៅបានប៉ះ មានបានវ៉ៃទេ?

ប៊ុនឡុង ៖ អត់បានប៉ះផង ចេញម៉ោវិញៗគេព័ទ្ធ ព័ទ្ធៗពួកខ្ញុំវ៉ៃទៅបាត់ អញ្ចឹងចេញម៉ោវិញអស់ម៉ោ ហើយចេញម៉ោវិញអស់ម៉ោ បានប៉ុន្មានថ្ងៃហ្នឹងគឺយើង រត់បានប្រហែលជាជិតកន្លះខែដែរ បានយើងពួកខ្ញុំចេញពីក្នុងម៉ោវិញ។

ដានី ៖ ដល់ពេលពូចូលទៅ ពូកាន់អាវុធអីគេចូលទៅ?

ប៊ុនឡុង ៖ បាទ!ខ្ញុំអត់មានអីទេ កាំភ្លើងដៃទេ កាំភ្លើងAKយើងហ្នឹង។

ដានី ៖ កាំភ្លើងAK?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ទៅជួយអញ្ចឹង យើងមានអារម្មណ៍ដូចថាខ្លាចភ័យអីទេ?

ប៊ុនឡុង ៖ រឿង ម្នាក់ៗវាអត់ខ្លាចទេ បាទ!អានេះខ្ញុំលើកដាក់ស្តែង ដូចយើងសព្វនេះចុះ កងទ័ពរាល់ថ្ងៃ ឥឡូវយើងអត់ចង់ធ្វើទេសង្គ្រាម តែថៃវាចង់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយវាចង់មិនត្រឹមតែចង់ធ្វើសង្គ្រាមទេ ហើយវាចង់បានប្រាសាទព្រះវិហារ ចង់បានអីយើង ហើយយើងកេរមរតករបស់យើង យើងម៉េចឲ្យគេ អញ្ចឹងអ្នកឯងចង់បានគឺយើងអត់ឲ្យ អញ្ចឹងអ្នកឯងវ៉ៃយើងមានសិទ្ធិការពារខ្លួន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងវាអត់នេះអី ដូចគ្នាអញ្ចឹងឯង យើងអត់ចង់ធ្វើសង្គ្រាមទេ តែឆ្នាំ៧៧គឺគាត់រំលោបយើងមុន ដូចគ្នា ។

ដានី ៖ បាទ!របស់យើង យើងការពារ?

ប៊ុនឡុង ៖ បាទ!អញ្ចឹងយើងការពាររបស់យើងដូចតែគ្នា ។

ដានី ៖ ចុះពូដល់ពេលឆ្នាំ៧៩ ដល់ពេលយួនបុកចូលម៉ោ ធ្វើម៉េចបានយើងទប់ទល់បាន?

ប៊ុនឡុង ៖ បាទ!អាហ្នឹងបើខ្ញុំនិយាយទៅ អាកន្លែងហ្នឹងដែលខ្ញុំអត់ចង់និយាយ ព្រោះវាបែកបាក់សាមគ្គីផ្ទៃក្នុង ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ខ្ញុំនិយាយប៉ុណ្ណឹងយើងដឹងហើយ ។

ដានី ៖ បាទៗ!ខ្ញុំអត់ដឹងដែរហ្នឹង ។

ប៊ុនឡុង ៖ បាទ!ព្រោះការបែកបាក់សាមគ្គីអញ្ចឹងយើងយ៉ាងម៉េច ធម្មតាសង្គ្រាមកំពុងតែធ្វើអញ្ចឹងប្រសិនជាបើយើងបែកបាក់គ្នាបានន័យថាដូចថាយើងបើកឲ្យ ឧទាហរណ៍ថាបែកបាក់គ្នាត្រង់អីត្រង់តែថា មួយទៅតាមតាររកអីអញ្ចឹងទៅ អញ្ចឹងយើងមិនពេញចិត្តអារបបហ្នឹងនោះណា៎ អារបបកម្ពុជាប្រជាធិបតេយ្យ អាដែងណែ៎ដូចណែ៎និយាយថារបបហ្នឹងវាសម្លាប់ អញ្ចឹងកន្លែងហ្នឹងហើយដែលយើងបែកបាក់គ្នា ដល់តែបែកបាក់គ្នាយើងម៉េចទប់ជាប់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាត់ការសាមគ្គីភាពហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងត្រូវតែបាក់ ។

ដានី ៖ ចុះពូកាលជំនាន់ពូធ្វើកងទ័ពនៅតាមព្រំដែន ពូមានដឹងថាគេកាប់សម្លាប់គ្នាមែនឬយ៉ាង ម៉េច?

ប៊ុនឡុង ៖ កន្លែងហ្នឹងខ្ញុំ វាយើងអត់បានម៉ោក្រោយ ហើយចន្លោះឆ្នាំ៧៥ មៅ៧៩ដែលយើងរត់ ហ្នឹងខ្ញុំអត់ដែលបានម៉ោក្រោយទេ អត់ដែលបានមៅដល់ស្រុកភូមិទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងអាហ្នឹងខ្ញុំអត់ដឹងទេ សភាពការណ៍ហ្នឹង ។

ដានី ៖ បាទ!ដូចជាកងទ័ពៗនៅតាមសមរភូមិនេះ មានដែលគេហៅ គេដកម៉ោហើយបាត់ មិនដែលឃើញទៅវិញ ឬក៏ពូដំណឹងថាគេចាប់គេសម្លាប់ដែរឬអត់ទេ?

ប៊ុនឡុង ៖ អាហ្នឹងយើងនិយាយទៅគឺថាខ្ញុំចាំឈ្មោះ អត់បាន តែជំនាន់នោះវាមានខ្លះ ។

ដានី ៖ មានអញ្ចឹងដែរ?

ប៊ុនឡុង ៖ បាទ!មានខ្លះ បាទ!មិនដឹងជាពាក់ព័ន្ធលើអីៗ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ព្រោះគេដកគេមិនឲ្យយើងដឹង ឧទាហរណ៍ថាឃើញបាត់មនុស្សម្នាក់ហ្នឹងទៅណា ។

ដានី ៖ បាទ!ហើយកាលជំនាន់ហ្នឹងបើតាមខ្ញុំធ្លាប់ជួបពូមីង ធ្លាប់អានឯកសារទៅដូចថា ខាង បូព៌ាអីហ្នឹង ដូចថា សោភឹម អីត្រូវបានគេចាប់ ហើយកងទ័ពខាងបូព៌ាត្រូវបានចាប់ ហើយសម្លាប់ច្រើនដោយសារ តែថាខាងបូព៌ាក្បត់អីអញ្ចឹង ពូមានដឹងរឿងទេ?

ប៊ុនឡុង ៖ អត់ដឹងទេៗ ព្រោះខ្ញុំទៅខាងស្វាយរៀងនេះ ខ្ញុំទៅក្រោយហើយ ។

ដានី ៖ ក្រោយហើយ?

ប៊ុនឡុង ៖ បាទ!គេទៅមុនៗមិនដឹងជាគេយ៉ាងម៉េចអីយ៉ាងម៉េចខ្ញុំអត់ដឹងទេណា៎ ។

ដានី ៖ បាទៗ!ព្រោះខ្ញុំសួរហ្នឹងក្រែលវាទាក់ទងនឹងពូមានប្រសាសន៍នឹងការបែកបាក់សាមគ្គី ក្រែលដោយសារវាមានបញ្ហាអញ្ចឹង ឬក៏យ៉ាងម៉េច?

ប៊ុនឡុង ៖ អាហ្នឹងមិនដឹងជាយ៉ាងម៉េចព្រោះខ្ញុំអត់ដឹងដែរ គ្រាន់តែពេលនេះហ្នឹងម៉ោ ពូថាអន្តភាព ខ្លះបេះ អន្តភាពខ្លះចុះ អញ្ចឹងអាហ្នឹងហើយដែលធ្វើឲ្យយើងដែលគេវៃនោះអត់មាន កម្លាំងទប់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែប៉ុណ្ណឹងទេ តែរឿងដែលថាសោ ភីម សោរអីហ្នឹងអត់ដឹងទេ អត់ដឹងរឿងទេ ។

ដានី ៖ បាទ!អត់ដឹងទេ?

ប៊ុនឡុង ៖ បាទៗ!ព្រោះគេទៅមុនឡើង២-៣វគ្គហើយហ្នឹង បានវគ្គក្រោយនេះគេឲ្យខ្ញុំទៅ រហូតដល់តទៅទៀត មានតាំងពីយើងណែ៎ភាគពាយ័ព្យនេះទៅជាមួយទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ទៅជួយទប់ទល់ ។

ដានី ៖ ពីពាយ័ព្យនេះទៅដែរ?

ប៊ុនឡុង ៖ បាទ!ទៅជួយទប់ទល់នៅហ្នឹងដែរ ។

ដានី ៖ អ្ហូ!ចុះកាលហ្នឹងពូមានស្គាល់តា ពីន ទេ តាពីនប្រធានកងពល៧០៣?

ប៊ុនឡុង ៖ បាទ!ខ្ញុំគ្រាន់តែឮតែឈ្មោះទេ តែខ្ញុំអត់ស្គាល់មុខទេ ។

ដានី ៖ អត់ដែរឮទេ?

ប៊ុនឡុង ៖ បាទ!គ្រាន់តែឮឈ្មោះតាពីនៗ នៅ៧០៣ ។

ដានី ៖ តាពីន?

ប៊ុនឡុង ៖ បាទ!តែឲ្យដឹងថា តាពីនហ្នឹងមុខម៉េចអីម៉េចទេ ។

ដានី ៖ បាទ!គាត់ស្លាប់ដែរ?

ប៊ុនឡុង ៖ មិនដឹងយ៉ាងម៉េចខ្ញុំអត់ដឹងដែរ ។

ដានី ៖ ព្រោះតាមពត៌មានឮថាគាត់ ពេលដែលយួនចូលហ្នឹងគាត់រត់ទៅ ហើយកងទ័ព ទាហានកូនចៅគាត់បាញ់គាត់ស្លាប់អីអញ្ចឹង?

ប៊ុនឡុង ៖ មិនដឹងម៉េចខ្ញុំអត់ដឹងដែរណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អត់ដឹងទេ

ដានី ៖ ចុះពូយ៉ាងម៉េចទៅ ដល់ពេលយួនម៉ោឆ្នាំ៧៩ ពេលយើងរត់ ហើយយើងរត់យ៉ាង ម៉េចតាមដំណាក់កាលយ៉ាងម៉េចបានពូមកដល់នេះ មកដល់ព្រំដែន?

ប៊ុនឡុង ៖ បាទ!អានេះបើនិយាយទៅ យើងជាយុទ្ធជនវាអត់មានដឹងការរឿងរ៉ាវផ្ទៃក្នុងខាងលើច្រើនទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គ្រាន់តែថា គេថាយើងត្រូវតែដក ដកទៅនេះ ដកទៅនោះអញ្ចឹងទៅ គេម៉ោៗទាំងគេទាំងអស់គ្នាអញ្ចឹងទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយគួរថាធ្វើម៉េចអីយ៉ាងម៉េច អាហ្នឹងអត់ដឹង គ្រាន់ថាគេប្រាប់ថាប៉ុណ្ណេះថា ត្រៀមរៀបចំលក្ខណៈ មានអន្ករដាក់ទែដាក់អីទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រោះយួនបុកចូលហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងយើងយុទ្ធជន មានដឹងការងារអីជ្រៅរាក់អីដូចគេមេៗទេ ដឹងតែអញ្ចឹង ឯង ។

ដានី ៖ បាទ!ដល់ពេលអញ្ចឹងពីក្រុងស្វាយរៀងនេះ យើងដកម៉ោពីកន្លែងណាទៅកន្លែងណា ទៅ?

ប៊ុនឡុង ៖ បាទ!ចេញមើស៍!ពីស្វាយរៀងម៉ោ បាទ!គេដកម៉ោ ម៉ោព្រៃវែង ខ្ញុំចាំបានព្រៃវែង ហើយចេញពីព្រៃវែងហ្នឹងកាត់ម៉ោរហូតហ្នឹង មិនដឹងកាត់កន្លែងណា អីកន្លែងណាខ្លះទេ ណ៎ បាទ!ដល់ពេលឡើងឆ្លងទន្លេឆ្លងអីម៉ោ ម៉ោឡើងចំស្ពានទឹកល្អក់ផ្លូវលេខ៥ហ្នឹង បាទ!កាត់ពីនោះម៉ោ កាត់ថ្នល់លេង៧ កាត់អីណា មិនស្រួលអាចំការលើ អាហ្នឹងបែបមានចូល ។

ដានី ៖ ស្ពានទឹកល្អក់នៅណាទៅ?

ប៊ុនឡុង ៖ បាទ!?

ដានី ៖ ស្ពានទឹកល្អក់?

ប៊ុនឡុង ៖ ស្ពានទឹកល្អក់ មើស៍ សាលាលេខ៥ កំពង់ឆ្នាំង ស្ពានទឹកល្អក់ ប្រឡោះកណ្តាល ។

ដានី ៖ បាទ!មុំកំពង់ឆ្នាំង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ បាទ!ម៉េចទៀតទៅពូ ដល់ពេលយើងម៉ោ?

ប៊ុនឡុង ៖ បាទ!ដល់ម៉ោដល់ហ្នឹង នៅហ្នឹងទៅមានការប្រយុទ្ធគ្នា២-៣ថ្ងៃអញ្ចឹងទៅ ដូចថាយើងទប់ទល់អត់បាននោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!មានការព័ទ្ធពីក្រោយព័ទ្ធអីអញ្ចឹងទៅ យើងដកចេញពីអាមាំមុំស្ពានទឹកល្អក់ហ្នឹងទៅម៉ោគគរ ។

ដានី ៖ បាទ! ម៉ោគគរពោសាធិ៍វិញ?

ប៊ុនឡុង ៖ បាទ! ម៉ោគគរអញ្ចឹងម៉ោប្រយុទ្ធគ្នាវ៉ៃនៅគគរហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ដល់វ៉ៃគ្នានៅគគរហ្នឹងហើយ អីហើយវ៉ៃមិនបែកអីអញ្ចឹងទៅ អញ្ចឹងវាមានដែនការមួយទៀត វាថាឥឡូវត្រូវម៉ោលាដ លាដកន្លែងខាងត្បូងយើងនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ម៉ោលាដហ្នឹងម៉ោៗ ខ្ញុំមិនដឹងនេះដែរ ប៉ុន្តែថានោះជំនាន់នោះគេថាមានចោរព្រៃ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងអន្តភាពតម្រូវឲ្យ ម៉ាវរៈសេនាតូចខ្ញុំហ្នឹងបោសសអាតចោរព្រៃនៅក្នុងតំបន់លាដមកដល់ភ្នំក្រវាញនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!មកដល់អូសោមភ្នំក្រវាញ ស្រែប្រាំងម៉ាជួរហ្នឹងទាំងអស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែទីចុងបញ្ចប់គឺ យើងត្រូវរត់ធ្លាក់មកដល់ដីថៃទៅវិញ ។

ដានី ៖ ដីថៃកន្លែងណាទៅ?

ប៊ុនឡុង ៖ បាទ!ដីថៃម៉ាម្តុំខ្លងយៃ ។

ដានី ៖ បាទ!ខ្លងយៃនៅហ្នឹងរយៈពេលប៉ុន្មានទៅ?

ប៊ុនឡុង ៖ នៅហ្នឹងរយៈពេល៣-៤ខែហ្នឹង ។

ដានី ៖ ម៉េចទៀតទៅដល់ពេលចេញពីខ្លងយៃ?

ប៊ុនឡុង ៖ ពេលនោះយើងៗ អ៊ូ!សុំទោស៣-៤ខែហ្នឹងយើងមិននៅក្នុងទឹកដីគេទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ យើងនៅព្រំដែនយើង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ! យើងចូលទៅក្នុង មុនដំបូងយើងចុះទៅចូលជំរុំបានមួយអាទិត្យដែរ ចូលក្នុងទឹកដីថៃ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយបានយើងចេញម៉ោនៅលើដីយើងវិញ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ វាលំបាកដែរ អាហ្នឹងពាក្យមួយ ពាក្យចាស់លោកថា"រត់ឃ្លួន ពួនថៃ" ។

ដានី ៖ អាហ្នឹងមានន័យថាម៉េចទៅ រត់ឃ្លួនពួនថៃ?

ប៊ុនឡុង ៖ ពីខាងកើតឃ្លួនដេញ ដល់យើងទៅថៃ ថៃវាធ្វើបាបខ្មែរ មុនដំបូង ដែលធ្វើបាបខ្មែរ មូលហេតុអី វាសួររកអ្នកកោះកុង ព្រោះកោះកុងខាងជើងទឹក អញ្ចឹងកោះកុងនេះវាធ្វើបាបថៃដែរ អញ្ចឹងថៃវាសួររកកោះកុង អញ្ចឹងនិយាយស្តីស្រួលមិនស្រួលវាចាប់ ទ័ព អញ្ចឹងអាហ្នឹងហើយដែលខ្ញុំប្រើពាក្យថា រត់ឃ្លួន ពួនថៃ ។

ដានី ៖ បាទ!ហើយម៉េចទៀតទៅចេញពីហ្នឹងម៉ោ?

ប៊ុនឡុង ៖ បាទ!ចេញពីហ្នឹងម៉ោ យើងនៅឡើងមកដីយើងម៉ោបានប៉ុន្មានខែគឺយើងជួបការលំបាក លំបិនវាច្រើនដែរណា ដែលប្រជាពលរដ្ឋអីគាត់រត់ទៅជាមួយយើងអញ្ចឹង ហើយគាត់ដាច់ស្រយាលពីអគ្គភាព ពីអីអញ្ចឹងទៅ ដែលពេលរត់ឡើងទៅហ្នឹង ល្មមធ្លាក់ដីថៃ អញ្ចឹងបងប្អូនក៏មានស្លាប់ច្រើនដែរ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ស្លាប់ដោយទីមួយហើមជើង ទីពីរគាត់ដាច់ចំណីអាហារ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងទំរាំបានធ្លាក់ដល់ទឹកដីថៃ អញ្ចឹងធ្លាក់ទៅដល់ទឹកថៃហើយ ឡើងម៉ោវិញ អញ្ចឹងពេលនោះថៃក៏ អើសមិនទាន់ជិតស្និតដូចម៉ោយើងអា៨៣-៨៤ឯណានោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!នៅ៧៩-៨០ហ្នឹងឯង អាហ្នឹងហើយយើងធ្វើមិនស្រួលគឺ វាអត់ឲ្យអគ្គរយើងហូប ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងហើយអាកន្លែងហ្នឹងហើយ យើងជួបការលំបាកច្រើន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងប្រជាពលរដ្ឋក៏គាត់ស្លាប់ច្រើនដែរ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!អាហ្នឹងការលំបាកៗក្នុងចិត្ត ៧៩ហ្នឹង ។

ដានី ៖ ៧៩?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដល់ពេល៨០?

ប៊ុនឡុង ៖ ដល់ពេល៨០ម៉ោ កងទ័ពមានហូបចុកគ្រប់គ្រាន់អស់វិញខ្លះ ។

ដានី ៖ បាទៗ!ដល់៨០ពូម៉ោនៅណាវិញទៅ?

ប៊ុនឡុង ៖ បាទ!ឆ្នាំ៨០ខ្ញុំម៉ោនៅហ្នឹង បាទ!ខ្ញុំម៉ោពីខ្ទង់ឃៃ ម៉ោចុះនៅខាងលិចនេះ ។

ដានី ៖ ចុះខ្មែរហ្នឹង?

ប៊ុនឡុង ៖ បាទ!ចុះខ្មែរហ្នឹង អញ្ចឹងចេញពីខ្មែរហ្នឹងទៅខាងជើងនោះបន្តិច បកពីខាងជើងម៉ោ វិញ ម៉ោនៅនេះឆ្នាំ៩០ ។

ដានី ៖ កាលហ្នឹងពូ យើងចូលពីហ្នឹងម៉ោៗនៅហ្នឹង កាលហ្នឹងពូធ្វើកងទ័ពដដែលឬក៏យ៉ាង ម៉េច?

ប៊ុនឡុង ៖ បាទ!ចំណោមអ្នករត់ម៉ោទាំងអស់គឺសុទ្ធជាកងទ័ព ។

ដានី ៖ អ្ហូ!ចុះពូជួបជាមួយមីងនៅឆ្នាំណាទៅ?

ប៊ុនឡុង ៖ បាទ!ឆ្នាំវាចុងឆ្នាំ៨១ ។

ដានី ៖ ចុង៨១?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ជួបមីងគាត់នៅហ្នឹងដែរឬក៏អត់ទេ?

ប៊ុនឡុង ៖ រត់ម៉ោដូចគ្នាទេ ។

ដានី ៖ រត់ម៉ោជាមួយគ្នាកាលហ្នឹង?

ប៊ុនឡុង ៖ គាត់គ្រាន់តែគាត់ម៉ោអន្តភាពគាត់ទៅ ខ្ញុំម៉ោតាមអន្តៗភាព ។

ដានី ៖ បាទ! ពូរៀបការឆ្នាំណា រៀបការជាមួយមីង?

ប៊ុនឡុង ៖ បាទ!៨១ ។

ដានី ៖ បាទ!៨១?

ប៊ុនឡុង ៖ បាទ!៨១ជិត៨២ ។

ដានី ៖ រៀបការនៅហ្នឹង?

ប៊ុនឡុង ៖ បាទ!អានេះយើងនិយាយមិនថាអីទេ ការនេះយើងជិនាន់នោះវាអត់ទាន់អស់អារបប នោះទេ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៈ យើងអត់ទាន់មានដែងណែ៎ អាហ្នឹងគេហៅថារបបរាស្រ្តសង្គមនិយមនោះណា ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ អេ៎អាហឹងគេហៅថារបបអ៊ី អាដែងណែ៎ ការទាំងគូរៗមួយជងមាន៤-១០គូរនេះៗ ព្រោះយើងអត់ទាន់អស់អាហ្នឹងទេ ។

ដានី ៈ នៅជាប់កំអែលពីនោះនៅឡើយ?

ប៊ុនឡុង ៈ នៅកំអែលនៅឡើយទេ ។

ដានី ៈ បាទ!ប៉ុន្មានគូរ កាលពូរៀបការ?

ប៊ុនឡុង ៈ បាទ!អានេះខ្ញុំតែម្នាក់ឯងទេ តែមួយគូរទេ ។

ដានី ៈ តែមួយគូរទេ?

ប៊ុនឡុង ៈ បាទ!

ដានី ៈ រៀបការយ៉ាងម៉េចទៅ យើងប្ដូរជ្ជាប្ដូចអី?

ប៊ុនឡុង ៈ បាទ!កាលហ្នឹងយើងមានស្អី គ្រាន់តែថាមានប្រធានអង្គភាពអញ្ចឹងម៉ោ ទទួលស្គាល់ ដឹងពូអីអញ្ចឹងទៅ ឲ្យចាប់ដៃគ្នា តែវាអត់មាននេះទេ ជំនាន់នោះដូចនេះអញ្ចឹង ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ គ្រាន់តែប្រកាសអ្នកនេះជាប្ដីប្រពន្ធ គ្មានមានភ្លេងមានភ្ញាត់អីដូចយើងឥឡូវនេះនោះ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ!

ដានី ៈ កាលហ្នឹងយើងដូចថា ខាងអង្គភាពគេរៀបចំឲ្យប្ដុក៏ពូស្គាល់គេ យើងស្នើរទៅត្រឹម ត្រូវ?

ប៊ុនឡុង ៈ បាទ!អញ្ចេះអានេះវា យើងដល់អញ្ចឹងទៅ ការនេះគឺយើងស្ម័គ្រចិត្តវាងគ្នាហើយនឹង គ្នាទេ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ!អត់មានគេចាប់ដាក់កាលយើងមិនទាន់រត់ចេញពីក្នុងស្រុកម៉ោទេ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ!នៅក្នុងស្រុក អាហ្នឹងខ្ញុំអត់សូវដឹងរឿងដែរ ប៉ុន្ដែគ្រាន់តែពុគេនិយាយថា ណែ មិត្តនេះ ត្រូវគូរជាមួយមិត្តនេះ ។

ដានី ៈ បាទៗ!

ប៊ុនឡុង ៈ បាទ!

ដានី ៖ បាទ!ខ្ញុំឮអញ្ចឹងដែរ ។

ប៊ុនឡុង ៖ បាទ!ដល់តែយើងរត់ម៉ោនេះគឺ យើងស្មគ្រចិត្តរៀងៗខ្លួនទេ បើឧទាហរណ៍ថាឈ្មោះ "ក" គាត់ពេញចិត្តឈ្មោះ "ខ" អញ្ចឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បើឈ្មោះ "ខ" ហ្នឹងឯកភាពអាហ្នឹងបានគាត់សុំរៀបបាន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែបើថាមួយស្រឡាញ់ហើយ ហើយមួយអត់ស្រឡាញ់ ក៏ខាងលើមិនអាចឲ្យយកបានដែរ ។

ដានី ៖ បាទ!អញ្ចឹងកាលពីពូចូលម៉ោដល់ហ្នឹង កាលហ្នឹងពូនៅក្នុងអង្គភាពអីដែរ ឬកងទ័ពកាលហ្នឹង?

ប៊ុនឡុង ៖ បាទ!នេះខ្ញុំម៉ោអាហ្នឹងវានៅនេះដែរ ប៉ុនគ្រាន់តែថាអង្គភាពមិនទាន់នេះ ដល់តែពេលក្រោយម៉ោបានគេដាក់អង្គភាពវរៈសេនាធំ៧០៣ ។

ដានី ៖ វរៈសេនាធំ៧០៣ កងពល?

ប៊ុនឡុង ៖ កងពលហ្នឹងមិនទាន់នេះទៀត អាហ្នឹងមានវរៈសេនាធំ កងពលវានៅឆ្ងាយណាស់ អាហ្នឹងបើយើងគិតទៅកាលហ្នឹង ពូកនជាគ្រប់គ្រងមិនដឹងជាកងពល ប៉ុន្មានទេ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ វានៅដូចថាម៉ាកងៗៗទៅ ។

ដានី ៖ បាទ!អញ្ចឹងនាយកនគាត់ជាអ្នកគ្រប់គ្រងដែរ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ គាត់គ្រប់គ្រងហ្នឹងផង នៅខាងសំពៅលូន នៅខាងភ្នំព្រឹកដែរ?

ប៊ុនឡុង ៖ បាទ!ដល់ក្រោយម៉ោបានមានលេខកងពល ។

ដានី ៖ កងពលប៉ុន្មានទៅ?

ប៊ុនឡុង ៖ អាហ្នឹង៣២០ តាប៉ៃ នេះ៧០៥ ។

ដានី ៖ កងពល៧០៥?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ៧០៥ពីណាគេប្រធាន?

ប៊ុនឡុង ៖ ប្រធានកាលនោះ ៧០៥ហ្នឹង ខ្មោចបងជាតិ ។

ដានី ៖ ឈ្មោះ ដាតិ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ គាត់ស្លាប់ពីអន្កាល់?

ប៊ុនឡុង ៖ ស្លាប់មុនសមាហរណកម្ម ។

ដានី ៖ អ្ហ៎!ស្លាប់ដោយសារអីគេហ្នឹង?

ប៊ុនឡុង ៖ គាត់ទៅសមរភូមិនៅមុខម៉ាឡៃ គ្រាប់ផ្លោង ។

ដានី ៖ គ្រាប់ផ្លោងពីខាងក្នុងម៉ោ?

ប៊ុនឡុង ៖ បាទ!ក្រោយម៉ោស្លាប់គាត់ទៅ បានឡើងបងថៃ ។

ដានី ៖ បងថៃ?

ប៊ុនឡុង ៖ បាទ!បងថៃហ្នឹងគាត់នៅកងពល រាល់ថ្ងៃនេះដែរ ។

ដានី ៖ ឥឡូវគាត់នៅកងពលដែរ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ កងពលលេខប៉ុន្មានទៅ?

ប៊ុនឡុង ៖ មិនដឹងលេខប៉ុន្មានទេណ៎ ព្រោះខ្ញុំឥឡូវ ខ្ញុំសម្រាកធ្វើទាហាន ឈប់ធ្វើតាំងពីសមាហរណកម្មម៉ោ ខ្ញុំឈប់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ខ្ញុំសុំគេឈប់ ។

ដានី ៖ បាទ!អញ្ចឹងអើ ប៉ុន្តែកងពលទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ នាយ កន គាត់គ្រប់គ្រងទាំងអស់?

ប៊ុនឡុង ៖ ពីមុន?

ដានី ៖ បាទ!ទាំងអស់ ទាំងមានការបែងចែកកងពល មានកងពល៣២០ មាកងពល ៧០៣?

ប៊ុនឡុង ៖ ៣២០ ៧០៥នៅក្រោមការគ្រប់គ្រងរបស់គាត់ ។

ដានី ៖ របស់គាត់?

ប៊ុនឡុង ៖ បាទ!

ដានី ៖ តាសុន សេនគាត់គ្រប់គ្រងពីលើទៀត?

ប៊ុនឡុង ៖ បាទ!ប៉ុនដល់ក្រោយម៉ោ មុនយើងសមាហរណកម្មហ្នឹង តាកននេះគ្រប់គ្រងតាំងពីកោះកុង ។

ដានី : តាំងពីកោះកុង?

ប៊ុនឡុង : បាទ!ឆ្ងាយដល់ គាត់ឡើងម៉ោនេះទៀតម៉ោ ។

ដានី : កោះកុង ពីថ្មបាំងអីហ្នឹង?

ប៊ុនឡុង : បាទ!ហ្នឹងហើយ តាំងពីហ្នឹងម៉ោ ឯកឧត្តម អៀង ផាន អីក៏នៅក្រោមគាត់ដែរ ។

ដានី : បាទៗ!

ប៊ុនឡុង : ក៏គាត់មិនដឹងធ្វើអីទេ ខ្ញុំអត់ដឹងដែរហ្នឹង ។

ដានី : ខ្ញុំអត់ដែលស្គាល់គាត់ដែលហ្នឹង ។

ប៊ុនឡុង : បាទ!

ដានី : បាទ!ហើយ អញ្ចឹងពូតាំងពីហ្នឹងម៉ោធ្វើកងទ័ព ដល់ពេលណាបានឈប់?

ប៊ុនឡុង : បាទ!ទាល់តែសមាហរណកម្មហ្នឹងឯង ។

ដានី : សមាហរណកម្ម៩៦ហ្នឹង?

ប៊ុនឡុង : ៩៦ខែ៧-៨ហ្នឹង ។

ដានី : ខែ៦ខែ៧?

ប៊ុនឡុង : បាទ!

ដានី : ចុះមីងគាត់នៅខាងកងដឹកជញ្ជូន?

ប៊ុនឡុង : ទេ!ពីមុនកាលគាត់មិនទាន់មានគ្រួសារ គាត់នៅខាងកងដឹកជញ្ជូន ដល់ពេលមានគ្រួសារទៅគឺមិនដែលទៅកងដឹកជញ្ជូនទេ មីងៗដែលមានគ្រួសារនៅផ្ទះនៅអីមើលកូន ។

ដានី : អូ!

ប៊ុនឡុង : បាទ!

ដានី : បាទ!ចុះពូដល់ពេលមានគ្រួសារហើយ នៅតែឡើងទៅសមរភូមិទៀតឬក៏យ៉ាងម៉េច?

ប៊ុនឡុង : បាទ!ឡើង ។

ដានី : សមរភូមិនៅខាងណាខ្លះទៅកាលហ្នឹង?

ប៊ុនឡុង : បាទ!សមរភូមិមានទល់មុខនេះក៏មាន ខាងត្បូងបាត់ដំបង ម្តុំបាត់ដំបងម៉ាជួរយើងខាងត្បូងស្ទឹង ។

ដានី : ខាងណាខ្ញុំអត់ដឹងដែរ?

ប៊ុនឡុង : ខាងត្បូងស្ទឹងហ្នឹង បានន័យថាតាំងពីមុខនេះម៉ោ មុខសំឡូត មុខនេះនោះ ។

ដានី : ចុះខាងសំឡូតមានកងពលគេដែរ?

ប៊ុនឡូង ៖ បាទ!គេមានកងពល ប៉ុនថាដល់អញ្ចឹងទៅ យើងទៅប្រឈរនៅ យើងចុះទៅហ្នឹងដើម្បីយើងមានកងអន្តរាគមន៍យើងនៅក្នុងទន្លេនោះ ។

ដានី ៖ បាទ!

ប៊ុនឡូង ៖ ក្នុងទន្លេសាប អញ្ចឹងយើងទៅនៅហ្នឹងដើម្បីទុកផ្លូវចេញចូល ។

ដានី ៖ តាកន គាត់គ្រប់គ្រងខាងសំឡូតដែរ?

ប៊ុនឡូង ៖ បាទ!ក្រោយម៉ោនេះប៉ុន្មានពី៩០ប៉ុន្មាននេះម៉ោហ្នឹង គាត់នេះហ្នឹង ពីមុនអត់ទេ គាត់តែនេះទេណា ។

ដានី ៖ បាទ!

ប៊ុនឡូង ៖ បាទ!ដល់យើងជិតសមាហរណកម្មនេះ គាត់គ្របគ្រង់តាំងពីហ្នឹង គាត់គ្រប់គ្រងនៅហ្នឹងតាំងពីឆ្នាំ៩០ ឬក៏៩០ប៉ុន្មានទេ ។

ដានី ៖ បាទ!កាលណីមុនហ្នឹងអត់ទេ?

ប៊ុនឡូង ៖ កាលពីមុនអត់ទេ ។

ដានី ៖ មានគេផ្សេង?

ប៊ុនឡូង ៖ មានគេបង្កើតអង្គភាពៗ ។

ដានី ៖ បាទៗ!តែប៉ៃលិនខាងម៉ាឡៃអត់ទេ?

ប៊ុនឡូង ៖ ពីមុនប៉ៃលិន អ៊ី ឈាន ។

ដានី ៖ បាទ!

ប៊ុនឡូង ៖ បាទ!ដល់ក្រោយមកទៀតបានរៀបចំទៅ តាកនហ្នឹងគ្រប់គ្រងដែរ ខាងម៉ាឡៃអ៊ីក៏គ្រប់គ្រងដែរ ខាងសំឡូតអ៊ី កោះកុងអ៊ីហ្នឹងគាត់ហើយ ។

ដានី ៖ បាទៗ!អញ្ចឹងកោះកុង សមរភូមិយើងនេះហ្នឹងយួនមកដល់ៗហ្នឹងដែរ?

ប៊ុនឡូង ៖ បាទ!ដល់ កន្លែងខ្លះដល់ កន្លែងខ្លះអត់ដល់ ប៉ុនភាគច្រើនព្រំដែនគឺដល់តែរហូតហ្នឹង ។

ដានី ៖ អ្ហូ!

ប៊ុនឡូង ៖ គ្រាន់តែថានៅមិនបានយូរ ។

ដានី ៖ នៅមិនបានយូរ?

ប៊ុនឡូង ៖ បាទ!

ដានី ៖ ចុះកាលពីសម័យ“ក៥”នោះកាលពីឆ្នាំ៨០ជាង ៨៤-៨៥សម័យ“ក៥”នោះយ៉ាងម៉េចដែរសម័យនោះ?

ប៊ុនឡុង ៖ បាទ!"ក៥" អាហ្នឹងវាអត់មានអីទេ ។

ដានី ៖ មានចូលម៉ោទេ?

ប៊ុនឡុង ៖ បាទ!ចូលម៉ោនេះ ខែ"ក៥" ខាងមុននេះមាន ប៉ុនឥឡូវដោះចង់អស់ហើយ ។

ដានី ៖ ដោះចង់អស់ហើយ?

ប៊ុនឡុង ៖ បាទ!ព្រោះគំរោងការរបស់រាជរដ្ឋាភិបាល គេថាធ្វើម៉េចកុំឲ្យខ្មែរក្រហមចូលម៉ោក្នុង ហ្នឹង អញ្ចឹងមិនយកមីនមករៀប ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងបានតាមព្រំដែនតាំងពីកោះកុង ឆ្លាយដល់ដងរែកនោះ "ក៥" ហ្នឹង និយាយទៅ បាទ!សឹងតែជុំវិញម៉ាប្រទេសហ្នឹង ដោយឡែកអត់"ក៥" តែព្រំប្រទល់យួន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងព្រំប្រទល់ថៃ យើងជាមួយអី ជាមួយអី ជាមួយឡាវ?

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!"ក៥" មានតែរហូតហ្នឹង ។

ដានី ៖ បាទ!ចុះកាលពីឆ្នាំហ្នឹងយួនមានដែលចូលមកដល់យើងហ្នឹងដែរ?

ប៊ុនឡុង ៖ ចូល ។

ដានី ៖ ចូលមកដល់ដែរ?

ប៊ុនឡុង ៖ បាទ!យើង"ក៥" ហើយចូលមកទៀត ។

ដានី ៖ ចូលម៉ោ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ចូលម៉ោហើយ យើងទៅណាវិញទៅ?

ប៊ុនឡុង ៖ បាទ!ការគេច ហើយនឹងការយើងវ៉ៃឈ្លប វ៉ៃឆ្មក់ទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ កន្លែងខ្លះនៅមិនបានក៏រត់ទៅវិញអស់ទៅ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ក្រោយម៉ោឆ្នាំប៉ុន្មាន ជិតសមាហរណកម្មនេះ ម៉ាជួរខាងមុខនេះ គឺយើងវ៉ៃបាត់ទៅ អស់វិញ ។

ដានី ៖ អ៊ូ!អញ្ចឹងកាលពេលដែលយួនចូលម៉ោដល់កន្លែងហ្នឹង ដូចថាគ្រួសារ កូនចៅ ប្រពន្ធ កូនអីយើងបញ្ជូនទៅដីថៃឬក៏យ៉ាងម៉េច?

ប៊ុនឡុង ៖ បាទ!អាហ្នឹងយើងចូលទៅដីថៃ ។

ដានី ៖ យូរដែរ ចូលទៅបានយូរដែរ?

ប៊ុនឡុង ៖ យើងចូល ក៏ចូលមិនជ្រៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ យើងចូលហើយ យើងរៀបចំកម្លាំងវ៉ៃវិញទៅ កន្លែងដែលយើងវ៉ៃមិនបែកទៅ វា នៅកៀកព្រំដែនយើងយកមកដាក់នៅឆ្ងាយពីហ្នឹងម៉ោ ហើយកម្លាំងការពារ កម្លាំនេះ ហ្នឹងទៅ ។

ដានី ៖ បាទៗ!ដល់ពេលយើងវ៉ៃបែក យើងបានមកវិញ កន្លែងហ្នឹងអី កាលហ្នឹងយ៉ាងម៉េច ដែរ មានមីនមានអីច្រើនដែរឬអត់កាលហ្នឹង?

ប៊ុនឡុង ៖ បាទ!អានេះសុំបញ្ជាក់ពីដើមឡើយ ដែលយើងវ៉ៃបែកដេញអស់ទៅ តំបន់នេះជាតំបន់ ព្រៃទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អត់មានវាលទេណា៎ ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ បាទ!ព្រៃទាំងអស់ បើនិយាយថានេះព្រៃសុទ្ធតែអាស្សីៗ អាស្សីធំជាងអាស្សីស្រុក ផងកន្លែងនេះ ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ បាទ!ដល់អញ្ចឹងយើងមកនៅ មុនដំបូងយើងមកនៅតាមមាត់អូរ ក្រោយម៉ោយើង ចេះតែពង្រីកៗម៉ោមុខម៉ោ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អាហ្នឹងវាអញ្ចឹង ។

ដានី ៖ ដូចដូង ដូចអីទីមដាំទេ?

ប៊ុនឡុង ៖ បាទ!ដូងហ្នឹងសុទ្ធទីមដាំទេ ព្រៃគឺទាំងអស់ អញ្ចឹងកសិផលដែលយើងដាំនេះ គឺសុទ្ធតែ ទីមដាំទាំងអស់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដូងបើសិនជានៅវិញ អត់មានកម្ពស់នេះទេ កម្ពស់នេះចង់២ដងហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រោះយើងមើលពីឆ្នាំ៩០មកដល់ឥឡូវវា២១ឆ្នាំហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ដីយើងតំបន់នេះដីល្អ គ្រាន់តែថាយើងដាំដូងអញ្ចឹងទៅ ឡើងបានកម្ពស់ៗហ្នឹង ដូងស៊ីកាប៉ែចស៊ីអីទៅ ងាប់អស់ទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អានេះខ្ញុំទឹមដាំសារៗក្រោយទៀតទេ បើថានៅអាមុនៗវិញងាប់ហើយ ។

ដានី ៖ បានហូបបាត់អស់ហើយ?

ប៊ុនឡុង ៖ មិនត្រឹមហូបទេ លក់ទៀត ព្រោះខ្ញុំ ខ្ញុំដាំច្រើនសឹងអីហ្នឹង ដាំ៥០-៦០ដើមនោះ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ប៉ុនតែសុទ្ធតែដូង អាដែងណែ៎!យើងយកខ្ទិកធ្វើនំបាន បើខ្ញុំដាំស៊ីអាអស់ពួកហ្នឹងហើយ អត់កើតបានខ្ញុំដាំ ខ្ញុំទិញដូងក្រអូបយកមកដាំវិញ ។

ដានី ៖ អ្ហូៗ!

ប៊ុនឡុង ៖ បាទ!បាននៅសល់ពួកអាអស់ហ្នឹងទៅ ។

ដានី ៖ អញ្ចឹងកាលពីចូលម៉ោហ្នឹងសុទ្ធតែព្រៃ?

ប៊ុនឡុង ៖ សុទ្ធតែព្រៃទេ ។

ដានី ៖ ប៉ុន្តែអត់មានមីនមានអីទេ?

ប៊ុនឡុង ៖ មីនវាចេះ វាមិនអត់ទេមីន មីនខ្មែរយើងដាក់ យើងដឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែដល់ពេលយើងដាក់ខ្សែអញ្ចឹង វាអត់សល់អាសាដៅទ័ព ផ្ទុះអស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងយើងដែលនៅសល់ចាំបាច់បំផុតខទាហរណ៍ថានៅ«ក៥» ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងមីនសល់ ឬមួយផ្លូវដែលយើងមានពីមុន៧៩ម៉ោនោះណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អាហ្នឹងមានមីនគោន មានមីនអីអញ្ចឹងទៅ នៅក្នុងដីអីអញ្ចឹងទៅ ។

ដានី ៖ មុន៧៩ទៀត?

ប៊ុនឡុង ៖ បាទ!ផ្លូវនេះ មីនយើងដាក់ត្រឹម៧៩ ដែលយើងរត់ម៉ោដល់នេះម៉ោហ្នឹងណាំ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ឆ្នាំ៨០ហ្នឹងយើងដាក់ហើយ តាមអាផ្លូវចាស់ៗពីមុន ដែលឈូសការពារព្រំដែននោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អាហ្នឹង ដល់អញ្ចឹងមកដល់សព្វថ្ងៃនេះគឺយើងមានមីនសល់ៗថាកន្លែងផ្លូវចាស់ បាទ!ប៊ុនអាផ្លូវចាស់ បើយើងអត់ដឹងៗដូចគ្នាដើរ ព្រោះឈើ៨-១០-២០ឆ្នាំវាដុះដើមប៉ុនៗនេះដែរហើយហ្នឹង កន្លែងផ្លូវៗហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ប៉ុនដល់បងប្អូនគេចំណាំបានអញ្ចឹងទៅ គេថាអានេះផ្លូវចាស់ណាស់កុំបំពាន កុំបើកអាត្រាក់បំពាន ប្រយ័ត្នផ្ទុះប្រយ័ត្នអី ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ប្រយ័ត្នប៉ុណ្ណឹងហើយ នៅតែមានគ្រោះថ្នាក់ទៀត អាត្រាក់នោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!វាអញ្ចឹង ។

ដានី ៖ បាទ!ពីព្រោះខ្ញុំមើលកាសែតទៅឮថាផ្ទុះ ឮថាស្អី?

ប៊ុនឡុង ៖ បាទ!ហ្នឹងហើយ ព្រោះយើងមិនទាន់ដោះអស់ទេ ។

ដានី ៖ មិនទាន់ដោះអស់មួយភាគរយទេអញ្ចឹងនេះ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ អញ្ចឹងនៅជុំវិញហ្នឹងមិនទាន់អស់មួយរយភាគរយទេ?

ប៊ុនឡុង ៖ បាទ!នៅក្នុងនេះ យើងនៅកន្លែងចំនុចសំខាន់ៗដែលស៊ីម៉ាក់ ដែលខ្ញុំជូនស៊ីម៉ាក់ទៅឧទាហរណ៍ថា នៅអូរក្រនោះគឺមានប៉ុន្មានកន្លែងអញ្ចឹង គេគូសទីតាំង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!នៅកន្លែងណាដែលនៅសល់ គេការពារគេគូសទីតាំង ហើយគេដាក់ផ្លាកទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!កុំឲ្យបងប្អូននេះ ប៉ុនអាវាមានមីនតូចៗ វាមិនសូវមានទេ វាមានអាមីនគោនប៉ុនៗនេះ ។

ដានី ៖ បាទ!អាតូចៗ អស់?

ប៊ុនឡុង ៖ បាទ!អាតូចៗ វាមិនអស់ទេ តែវាមាននៅដោយកន្លែងណា៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!កន្លែងដែលយើងហាមឃាត់អីអញ្ចឹងទៅ មិនឲ្យចូលទេ ខ្លាចព្រោះថ្នាក់ ។

ដានី ៖ បាទ!ចុះពូឈប់ធ្វើកងទ័ពតាំងពីឆ្នាំណាម៉ោ?

ប៊ុនឡុង ៖ បាទ!យើងសមាហរណកម្ម ៩៦ ខែប៉ុន្មាននេះមិនដឹង ម៉ោ៩៧ខ្ញុំសុំគេឈប់ម៉ង ។

ដានី ៖ ឈប់ម៉ង?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ម៉េចបានពូឈប់ពីកងទ័ព ហេតុអី?

ប៊ុនឡុង ៖ អញ្ចឹងអាកន្លែងហ្នឹងហើយ យើងក៏ថានេះ ព្រោះអានេះ ដូចថាប្រទេសចប់សង្គ្រាម ហើយឈប់ធ្វើកងទ័ព ព្រោះពីមុនយើងគេចមិនបាន យើងទៅណាក៏គេចមិនផុត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ត្រូវតែធ្វើ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ដល់ឥឡូវវាចប់ទៅហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ នឹកឃើញថា សុំគេ គេមិនឲ្យយើងឈប់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ប៉ុនដល់យើងសមាហរណកម្ម យើងត្រូវគ្នា ទាំងក្នុងទាំងក្រៅហើយ មានណាវ៉ៃណាទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងខ្ញុំសុំឈប់ទៅ គេមិនឲ្យយើងឈប់ទេ បើនៅធ្វើរាល់ថ្ងៃ ក៏ខ្ញុំធ្វើប៉ូលីសធ្វើអីដែរ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ប៉ុនដល់អញ្ចឹងសុំគេឈប់ទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គេឲ្យឈប់ អញ្ចឹងបានមានអ្នកខ្លះម៉ោថា ដល់របបស៊ីប្រាក់ខែហើយ បងឯងឈប់ ខ្ញុំថាបងប្អូនបានទទួលប្រាក់ខែក៏ទទួលចុះខ្ញុំអត់ថាអីទេ រឿងឈប់ជារឿងរបស់ខ្ញុំទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងមកទល់សព្វថ្ងៃនេះ ខ្ញុំអត់មានជាប៉ូលីស ជាទាហានអីទៀតទេ ។

ដានី ៖ បាទ!ពូធ្វើស្រែចំការសុទ្ធ?

ប៊ុនឡុង ៖ បាទ!ធ្វើស្រែចំការជាប្រជាពលរដ្ឋ ។

ដានី ៖ ចុះពូបានទៅលេងស្រុកភូមិកំណើតដែរ?

ប៊ុនឡុង ៖ បាទ!ខ្ញុំទៅតាំងពី៩៧ គ្រាន់តែសមាហរណកម្ម៩៧ខ្ញុំទៅ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ បាទ!ទៅថ្នល់ជាតិលេខ៥អត់ទាន់មាននេះទេណា៎ ឡានទៅជាប់កណ្ដាលៗថ្នល់ ហើយនៅមានករណីចោរប្លន់ចោរអីឡើងហូរហែរ ខ្ញុំព្រួយដែរហ្នឹងអាស៎ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ ប៉ុនធ្វើម៉េចនឹកឃើញថាបែកម្ដាយ បែកបងប្អូនវាយូរឆ្នាំពេកទៅ ។

ដានី ៖ អ្ហូ!បែកប៉ុន្មានឆ្នាំ?

ប៊ុនឡុង ៖ វា៣០-៤០ឆ្នាំទៅហើយ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ អញ្ចឹងគឺយើងបានចប់ហើយ គឺយើងគួរតែទៅរកគាត់ រកឪពុកម្ដាយ រកបងប្អូនឲ្យដឹងថាយើងនៅរស់ ។

ដានី ៖ បាទ!គាត់អត់ដឹងដំណឹង?

ប៊ុនឡុង ៖ បាទ!គាត់អត់ដឹងទេ ម្ដាយខ្ញុំគាត់ឲ្យគេមើលៗអីទៅ គេថាអេស៎កូននៅទេ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ អញ្ចឹងអ្នកខ្លះទៅ ថាមិនបាច់នេះកូនស្លាប់បាត់ទៅហើយ ។

ដានី ៖ អ្ហូ!

ប៊ុនឡុង ៖ អាករណីហ្នឹងហើយ ដែលខ្ញុំគ្រាន់តែចប់៩៧គឺខ្ញុំទៅភ្លាម ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ពីនេះជិះឡានទៅដល់បាត់ដំបងមួយថ្ងៃពេញ ។

ដានី ៖ អ្ហ៎! បាទ ។

ប៊ុនឡុង ៖ គាត់ព្រៃ គាត់នេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយពីបាត់ដំបងទៅដល់ភ្នំពេញមាំថ្ងៃពេញទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ មិនដូចឥឡូវ ប៉ុន្មានម៉ោងដល់ទេណា៎ ។

ដានី ៖ ឥឡូវពីម៉ោ១-២ដល់ភ្នំពេញបាត់ហើយ ។

ប៊ុនឡុង ៖ បាទ! ហ្នឹងអញ្ចឹងហើយ ។

ដានី ៖ ដល់ពេលពូទៅដល់ដំបូងយ៉ាងម៉េចដែរ ទៅដល់ស្រុកភូមិនោះបែកយូរ?

ប៊ុនឡុង ៖ ទៅដល់ស្រុកភូមិនោះ ខ្ញុំនិយាយបន្តិចចុះរឿងហ្នឹង សួរទៅក្មេងៗក្រោយគេអត់ស្គាល់ផងហ្នឹង ។

ដានី ៖ អត់ស្គាល់ពូ?

ប៊ុនឡុង ៖ អត់ស្គាល់ទេ ខ្ញុំសួរម្ដាយខ្ញុំក្មេងៗខ្លះអត់ស្គាល់ ដល់ពេលសួរប៉ះចាស់ៗ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ចាស់ៗពេលគាត់ឃើញគាត់ស្គាល់ គាត់ថាអាអូនឯងម៉ោហើយ បាទ! ខ្ញុំទៅដល់ផ្ទះម្ដាយខ្ញុំយំណាស់ គាត់រំភើបពេកនោះ ។

ដានី ៖ អ្ហ៎!

ប៊ុនឡុង ៖ ចុះបាត់កូន៣០-៤០ឆ្នាំហើយ ។

ដានី ៖ អត់ដែលមានទាក់ទងតាមសំបុត្រទេ?

ប៊ុនឡុង ៖ អត់! អត់ដែលសោះ ដល់អញ្ចឹងទៅ ទៅឃើញដូចថា គាត់អរគាត់ ។

ដានី ៖ គាត់មើលស្គាល់ទេ?

ប៊ុនឡុង ៖ គាត់នៅមើលស្គាល់ ហើយម្ដាយខ្ញុំក៏នេះអញ្ចឹងទៅ អញ្ចឹងបានគាត់ គាត់ថានេះដែរ គាត់ថាកូនអើយម៉ោនៅស្រុកទៅ ខ្ញុំថាម៉ែអើយ! ស្រុកគេចប់សង្គ្រាមហើយ ម៉ោមានដីមានធ្លីឯណា ខ្ញុំនៅឯនេះម៉ោគ្រាន់ខ្ញុំមានដីមានធ្លីគ្រាន់ឲ្យកូនចៅខ្ញុំធ្វើចំការ ធ្វើស្រែខ្លះ បើនៅនោះយើងមានដីធ្លីយើងចែកគ្នាអស់ហើយ ខ្ញុំចែកបានអីនឹងគេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ទៅនៅនោះទាល់តែករណីមានលុយ ទិញគេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយខ្ញុំអត់មានលុយទិញ មានអី បើនៅនេះខ្ញុំអាចចាប់បាន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គ្រាន់បានដីឲ្យកូនធ្វើស្រែ ធ្វើចំការខ្លះទៅ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អញ្ចឹងទៅ ក៏គាត់នេះទៅ អញ្ចឹងដូចរាល់ថ្ងៃសភាពការណ៍មិនសូវស្រួលអញ្ចឹង គាត់ច្រើនតែគេម៉ោថា កូនបើថាមិនស្រួលទេទៅ ខ្ញុំថាអត់ទាន់អីទេ ។

ដានី ៖ តាមព្រំដែន យើងរៃជាមួយថៃ ជាមួយអីហ្នឹង?

ប៊ុនឡុង ៖ ហ្នឹងហើយ ហើយបើសិនជាយើងអាល្មមៗយើងទៅ តែទៅខ្ញុំជឿថាគេកាស់ផ្ទះ គាត់អីយកអ៊ីវ៉ាន់អស់ឥឡូវហ្នឹង ។

ដានី ៖ នៅនេះ?

ប៊ុនឡុង ៖ យី!បើសិនជាករណីហ្នឹងថា ឥឡូវយើងអាដែងណែ! យើងរត់ចោលផ្ទះ អញ្ចឹងតែរត់គេកាស់ហើយ កុំប្រឡំនោះ អាអ្នកខូច ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អាហ្នឹងអញ្ចឹង អញ្ចឹងអ្នកឯងមិនខ្លាំងជាងខ្ញុំប៉ុន្មានទេ បើអ្នកឯងរត់អស់ បានខ្ញុំរត់អស់តែមិនស្រួលអត់រត់ទៀត ទាហានម៉ោ ធម្មតាតែសង្គ្រាមហើយគេមិនដែលទុកឲ្យយើងដែរទេទេ ព្រោះគេធ្លាប់ដឹង គេអ្នកធ្វើសង្គ្រាមដែលនោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងគេមានអ្នករួមកម្លាំងឲ្យយើងនៅជាមួយគេវិញទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដើម្បីការពារទឹកដី ដើម្បីការពារផ្ទះសម្បែងយើង ។

ដានី ៖ បាទៗ!ចុះបងប្អូនទៅ នៅស្គាល់គ្នាដែរ?

ប៊ុនឡុង ៖ បាទ!នៅ គេរាល់ថ្ងៃនឹងខ្ញុំ ។

ដានី ៖ បាទ!ប៉ុន្តែពួកទៅតែឆ្នាំ៩៧ យើងមិនដែលជួបគ្នាសោះ?

ប៊ុនឡុង ៖ បាទ!ខ្ញុំទៅស្គាល់ បងប្អូនខ្ញុំ ខ្ញុំអត់ចេះនេះទេ អញ្ចឹងមានបងប្អូនខ្លះគេថាទៅឯងអត់ខ្លាចវង្វេងផ្ទះវង្វេងអី រកផ្ទះមិនឃើញ ខ្ញុំថាស្លាប់ហើយ រឿងស្រុកភូមិខ្ញុំ បងប្អូនខ្ញុំ

ទោះបីខ្ញុំដើរចោរ៣០-៤០ឆ្នាំក៏ដោយ ខ្ញុំអត់មានភ្លេចទេ សូម្បីតែកូនប្រសារខ្ញុំស្រី វីន អាហ្នឹងក្មួយខ្ញុំបង្កើតហ្នឹង

ដានី : មកពីស្រុក?

ប៊ុនឡុង : បាទ!ម៉ោពីស្រុកម៉ោនឹងឯង ចាស់ៗគាត់ថាហ៊ីអាស! បើអ្អូង អញ់ឲ្យវាយកហ្នឹង ហើយ បើមិនចឹងអ្អូងអត់ម៉ោស្រុកទេ ដល់សួរកូននោះ កូនគេថាស្រាច់តែយាយតា ម៉ែឪ បងប្អូនគេទុកដាក់ អ៊ើ!ខ្ញុំឯកភាពតាមបងប្អូនទៅ ទឹមម៉ោពីផ្ទះយប់ម្សិលទេ ទៅ ការប្អូនគេនោះ ។

ដានី : បាទៗ!ចុះដូចថាសាច់ញាតិ អ្នកស្រុកអ្នកភូមិ ហើយមិត្តភក្រ័ពូកាលពីក្មេងៗ ដល់ ពេលពូទៅ នៅតែស្គាល់គ្នា រាប់ រាក់ទាក់ជាមួយគ្នាដែរឬក៏យ៉ាំងម៉េច?

ប៊ុនឡុង : អត់អីទេ ស្គាល់ ហៅគ្នា រាប់អានគ្នា ខ្វះទៅក៏អន្តុយនិយាយ ហ៊ុ!អញស្មានតែអ្អូង ស្លាប់បាត់ហើយ បានខ្ញុំប្រើពាក្យមួយមាត់ខ្ញុំថា ពូជអញធិនវង្ស គ្រាន់តែកំសត់បន្តិច តែរឿងស្លាប់មិនស្លាប់ទេ ។

ដានី : បាទ!

ប៊ុនឡុង : ព្រោះវា អញ្ចឹងបានខ្ញុំនិយាយអញ្ចឹងណា៎ កាលធ្វើសង្គ្រាម ការអី អញ្ចឹងការវៃចូល ដល់ណាៗខ្ញុំអត់ គឺខ្ញុំចិត្តខ្ញុំត្រង់ អត់លោភលន់ទ្រព្យសម្បត្តិគេទេ ។

ដានី : បាទៗ¡

ប៊ុនឡុង : ព្រោះអ្នកលោភលន់ព្រទ្យសម្បត្តិចង់បានស្អីៗគេហ្នឹង គឺចុងបញ្ចប់គឺបាត់បង់ទ្រព្យ សម្បត្តិ ។

ដានី : បាទៗ!

ប៊ុនឡុង : អញ្ចឹងខ្ញុំការធ្វើសង្គ្រាមប៉ុន្មានឆ្នាំម៉ោ មែនថាយើងនេះទេ យើងនៅតែបន់ស្រន់ ។

ដានី : បាទ!

ប៊ុនឡុង : បាទ!គុណម៉ែគុណឪ ទឹកដោះថ្លៃ ដែលតាមថែរក្សាកូនចៅ អញ្ចឹងកូនចៅអត់មាន បំពានលើអីទេ ។

ដានី : ពូជឿហ្នឹងដែរ?

ប៊ុនឡុង : ព្រោះដល់អញ្ចឹងទៅយើងមិនមានការគ្រោះថ្នាក់អីប៉ុន្មានទេ ខ្ញុំតាំងពីរត់យួនម៉ោ មក ទល់ដល់ពេលនេះខ្ញុំអត់ដែលមានត្រូវរបួសទេ ។

ដានី : បាទ!

ប៊ុនឡុង ៖ អញ្ចឹងត្រូវរបួសអាប៉ុកពីពាន្នាំនោះ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អា៧៧-៧៨-៧៩នោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងខ្ញុំត្រូវ៤-៥ដង អាហ្នឹង ។

ដានី ៖ បាទ!ចុះពូទៅលេងផ្ទះ ទៅលេងយូរៗដែរប៉ុក៏?

ប៊ុនឡុង ៖ បាទ!ខ្ញុំទៅជួនកាលមួយខែអីនោះ ។

ដានី ៖ អ៊ូ!យូរដែរអញ្ចឹង?

ប៊ុនឡុង ៖ បាទ!ដើរទៅផ្ទះបងប្អូនអីអញ្ចឹងទៅ អញ្ចឹងបានស្គាល់ទៅរហូតទៅដល់ខ្ញុំមានក្មួយ មាន ប្ដីមានប្រពន្ធនៅសៀមរាប ខ្ញុំទៅសៀមរាបទៅលេងអង្គរលេងអីហូរហែរអញ្ចឹង ។

ដានី ៖ អ៊ូ!

ប៊ុនឡុង ៖ ក្មួយៗនៅហ្នឹង គេធ្វើការធំៗនោះ គេខាងភ្ញៀវអញ្ចឹងទៅ គេប្រធានភ្ញៀវអីអញ្ចឹងទៅ គេប្រាក់ខែគេរាប់ពាន់ដុល្លានោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដល់យើងទៅលេងទៅ ផ្ទះគេ៥៣-៤ជាន់គេឲ្យទៅដេកឲ្យនៅហ្នឹងទៅ ហើយគេមាន ឡានមានអីគេជូនដើរលេងអញ្ចឹងទៅ ។

ដានី ៖ អ៊ូ!បាទ ។

ប៊ុនឡុង ៖ អញ្ចឹងបានខ្ញុំថានៅនេះ នៅតែម្នាក់ឯងក៏ថាបាន បងប្អូននៅរាល់ថ្ងៃនោះ តាមពិតទៅ នៅស្រុកនៅតែប្អូនពៅតែមួយនាក់ទេ ក្រៅពីហ្នឹងគេនៅភ្នំពេញអស់ ។

ដានី ៖ អ៊ូ!ទៅនៅភ្នំពេញអស់ហើយ?

ប៊ុនឡុង ៖ ទៅនៅភ្នំពេញតាំងពី ។

ដានី ៖ ៧៩?

ប៊ុនឡុង ៖ អត់ទេ!ក្រោយម៉ោទៀត ប្រហែលជាអាច៩០ហ្នឹងឯង ប៉ុនគេទៅគេមានការងារធ្វើ គេមានប្រាក់ខែ មានអីទៅបងៗ ប្អូនគេក៏មានខ្លះទៅ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អាប្អូនមួយក៏គេនៅស្រុកទៅ វរៗគ្មានណានៅស្រុក អញ្ចឹងបានទៅ ទៅចូលភ្នំពេញ ផង ហួសចូលស្រុកផង ។

ដានី ៖ បាទ!ចុះពូទៅយូរអញ្ចឹង នឹកម៉ោនេះវិញឬអត់?

ប៊ុនឡុង ៖ បាទ!អត់អីទេ ការធ្វើដំណើរដើរអញ្ចឹង ព្រោះខ្ញុំធ្លាប់ដើរវាដូចនេះហើយ ទៅមិនចេះនឹកកន្លែងទេ ។

ដានី ៖ អត់នឹក?

ប៊ុនឡុង ៖ បាទ!ព្រោះគិតមើលៗយើងតាំងពីនេះម៉ោ ខ្ញុំដើរចោលស្រុក មុនដំបូងខ្ញុំចេញទៅធ្វើកងទ័ពដែលចប់ហើយ ឆ្នាំ៧៥-៧៦ហ្នឹងអាលកយំក្រូឡើង នឹកឃើញផ្ទះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ប៉ុនដំនាន់នោះ វាដល់ដំណាក់ហើយ ប្រសិនជាយើងតាំងចិត្តមិនបាន យើងរត់ម៉ោផ្ទះគេចាប់បានគេវ៉ៃយើងចោល ។

ដានី ៖ អ្ហូ!ពូដឹងដែរអាហ្នឹង?

ប៊ុនឡុង ៖ ព្រោះអាហ្នឹងវាអាចនេះបន្តិចដែរហ្នឹង ប៉ុនគ្រាន់តែថាយើងមិនដឹងខាងក្រោយយ៉ាងម៉េចអីយ៉ាងម៉េច ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងប្រសិនជាអ្នករត់ម៉ោ ក្នុងអន្តភាពរត់ម៉ោគេចាប់បាន មិនដឹងជាគេយ៉ាងម៉េចដូចខ្ញុំបាននិយាយថា យូរឃើញមានបាត់មួយអញ្ចឹង អត់ឃើញអញ្ចឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងមិនដឹងជាគាត់ហ្នឹងរត់ អីក៏យ៉ាងម៉េច ។

ដានី ៖ បាទៗ!ប៉ុន្តែម្យ៉ាងទៀត ដូចថាពូរស់នៅនេះតាំងពី៧៩-៨០អីម៉ោរហូត មកដល់ឥឡូវវា៣០-៤០ឆ្នាំម៉ោដែរ?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដូចថាៗនេះដូចជាភូមិកំណើត ដូចជាផ្ទះពូ ពូមានមិត្តភក្រ្ត ទោះជាគាត់ម៉ោពីកន្លែងម៉ោពីខេត្តផ្សេងៗម៉ោ ប៉ុន្តែរស់នៅនេះយូរហើយ ពូយល់ឃើញម៉េចដែរ ដូចថានៅវាមានការជិតស្និតជាងនៅហ្នឹងឬយ៉ាងម៉េច?

ប៊ុនឡុង ៖ វាអញ្ចឹងដែរ វាអត់ខុសអីទេ វាមានស្រុកកំណើតនៅនោះមែន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែយើងមានតែស្រុកកំណើតទេ តែដីធ្លីសម្រាប់ធ្វើស្រែ ចំការ យើងអត់មានទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងកន្លែងនេះយើងមានពិធីធ្វើបុណ្យ ស្រែទាំងអស់ អញ្ចឹងណាស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងការទៅ ការនេះយើងមានការគិតខ្លះដែរ វាមិនមែនថាអត់ទេ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!ត្រង់ថាយើងដើរយូរអញ្ចឹងទៅ មិនដឹងថាកូនចៅនៅផ្ទះវាធ្វើអី នៅអីទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រោះការទៅលេង ការទៅស្រុកកំណើតនេះគឺ វាជាស្រុករបស់យើងហើយ ដូចខ្ញុំបាននិយាយខាងដើមអញ្ចឹង ស្រុកមែនតែវាអត់មានអីណាយើង មានតែខ្លួនទៅហ្នឹង ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ដូចថាទៅលេងម្ដាយ លេងបងប្អូន លេងញាតិមិត្តជិតខាង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ដែលយើងធ្លាប់ស្គាល់ ពូមីងអីអញ្ចឹងទៅ ។

ដានី ៖ បាទ!ចុះពូដូចថាអ្នកជិតខាងគ្នានៅនេះ យើងរាប់អានគ្នា យ៉ាងម៉េចដែរ យើងនៅនឹកខ្លះដែរ ឬក៏មិនសូវទេ?

ប៊ុនឡុង ៖ បាទ!អានេះនិយាយទៅ ការរាប់អាននេះចាត់ថា បងប្អូនទាំងអស់ដែលនៅជិតៗខាងហ្នឹងគឺ អត់មាននៅស្រុកជិតៗគ្នាទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែចំណុចពិសេស យើងសាមគ្គីភាពគ្នា ចាត់ទុកញាតិមិត្តជិតខាងចាត់ទុកដូចបងប្អូន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ព្រោះបានខ្ញុំចាត់ទុកដូចបងប្អូន ការឈឺឆ្កាត់ ការមានធុរៈទៅ អ្នកដែលជិតខាងហ្នឹង ហើយដែលជួយគ្នាទៅវិញទៅមោ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងចាត់ទុកថា គាត់ជាបងប្អូនទី២ក៏បានដែរ ។

ដានី ៖ បាទៗ!ចុះពូមួយទៀត ពូយល់ឃើញយ៉ាងម៉េចដែរ ដូចថាកាលពីសម័យសង្គ្រាមមុនយើងមិនទាន់ ពីមុនសមាហរណកម្ម ហើយក្រោយសមាហរណកម្មមកដល់សព្វថ្ងៃនេះវាមានការខុសគ្នាយ៉ាងម៉េចដែរ?

ប៊ុនឡុង ៖ បាទ!អញ្ចឹងពីមុន សមាហរណកម្មដែលយើងនៅវិញ្ញាហ្នឹង វាខុសប្លែកគ្នាឆ្ងាយពីសព្វថ្ងៃនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ពីមុនយើងគ្មានពេលធ្វើចំការ គ្មានពេលទៅលេងស្រុក ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!គ្មានពេល ឧទាហរណ៍ថាដូចសព្វថ្ងៃចង់ទៅនេះទៅនោះបានស្រេចចិត្តអត់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!បើយើងចង់ទៅណា ម៉ោណា ទាល់តែសុំ ហើយជំនាន់នោះយើងមិនអាច មេខ្ញុំសុំទៅស្រុក២-៣ថ្ងៃបានទេ គេអត់ទេ តែយើងសុំទៅស្រុកតែមិនស្រួលគេតាមដានយើងទៀត ខាងក្នុងក៏អញ្ចឹងដែរ ដូចតែគ្នា ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អញ្ចឹងមកដល់សមាហរណកម្មមកទល់ហើយ វាខុសប្លែកគ្នាឆ្ងាយណាស់ បាទ!ឆ្ងាយទី១យើងមានសិទ្ធិសេរីភាព យើងចង់ធ្វើទាហានមិនធ្វើទាហានស្រេចតែយើង យើងសុំឈប់បាន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ទី២ យើងមានសិទ្ធិធ្វើស្រែធ្វើចំការ មានសិទ្ធិដើរទៅស្រុក ទៅលេងស្រុកទៅអីណាកន្លះខែមួយខែអី ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អត់មានណាតាមសួរ តាមរកអី ពួកយើងទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយសខាន់បំផុត គឺចង់បានសន្តិភាព ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ព្រោះវាសង្គ្រាមម៉ាអាយុកាល ខ្ញុំអាយុ៥០ជាងនេះ វាដល់៣ដងហើយ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!ខ្ញុំអត់ចង់បានទៀតទេ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!ចង់បានតែសាន្តត្រាន អញ្ចឹងរាល់ថ្ងៃនេះ ខ្ញុំឃើញថាយើងតាមព្រំដែនមានការវិវាទជាមួយថៃ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងគំនិតរបស់សម្តេចតេជោ បាទ!គាត់ធ្វើត្រឹមត្រូវណាស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បានខ្ញុំថាត្រឹមត្រូវគាត់មិនចង់ឲ្យយើងមានសង្គ្រាមទៀត អញ្ចឹងការដោះស្រាយ បាទ! ដោះស្រាយដោយនីតិវិធីបាទ! អត់មានដោះស្រាយយកអាវុធទៅដោហស្រាយទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ តែកាលៈទេសៈដែលគេចង់បានទឹកដីយើងហើយ យើងបានប្រកាសហើយតាស់! ១មីលីម៉ែត្រក៏មិនឲ្យអ្នកឯង យើងក៏មិនចង់បានអ្នកឯង១មីលីម៉ែត្រដូចគ្នា ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងសម្រាប់ខ្ញុំក៏ដោយ សម្រាប់មតិបងប្អូនចង់បានសន្តិភាពដូចគ្នាទាំងអស់ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ហើយអាពីប៉ុន្មានឆ្នាំមុនចាត់ទុកថា អាហ្នឹងជារឿងហួសទៅហើយ ។

ដានី ៖ បាទ!តែមួយទៀតពូ ដូចថាខ្ញុំបានជួបពូមីងខ្លះគាត់ថា កាលពីមុន កាលយើងនៅ សង្គ្រាម យើងអត់ភ័យបារម្ភថា យើងអត់ខ្វះអង្ករ យើងភ័យបារម្ភថាយើងមិនចាំ បាច់ធ្វើអី យើងមានរបប យើងមានអីហូប?

ប៊ុនឡុង ៖ បាទ!

ដានី ៖ ដល់ឥឡូវនេះគេអត់មានគិតគូរយើងទេ យើងត្រូវរកខ្លួនឯង យើងត្រូវធ្វើខ្លួនឯង យើងបាន បានហូប បើយើងអត់បាន អត់បានហូប អាហ្នឹងចំពោះពូ ពូគិតយ៉ាងម៉េច ដែរហ្នឹង?

ប៊ុនឡុង ៖ បាទ!ខ្ញុំអត់គិតដល់អញ្ចឹងទេ ព្រោះយើងរាល់ថ្ងៃនេះ ឥឡូវយើងទូទៅ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!យើងធ្វើដូចគ្នា ខ្ញុំគិតថាខ្ញុំមើលឃើញនៅក្នុងនេះ អញ្ចឹងរាល់ថ្ងៃនេះ មានភូមិ មានឃុំដឹកនាំ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ មានភូមិ មានឃុំដឹកនាំ អញ្ចឹងប្រសិនជាប្រជាពលរដ្ឋម្នាក់ណា ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ដែលគាត់អត់ ឧទាហរណ៍ថាគាត់ជរាអញ្ចឹងចុះណា៎ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ គាត់ធ្វើអីមិនកើតៗ ប៉ុន្តខ្ញុំជឿថាគាត់មិនដែលថាអត់បងប្អូន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!គាត់ត្រូវតែមានបងប្អូន អញ្ចឹងបងប្អូនត្រូវការជួយគាត់ហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងមួយ មួយទៀតបើសិនជាករណីដែលគាត់អញ្ចឹងហើយ យើងរាយការទៅលើ ទៅទៀត តាមរយៈអាជ្ញាធរភូមិឃុំទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!ព្រោះសម្តេចបានមានប្រសាសន៍ហើយតាស៎ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!មិនឲ្យដាច់ពោះស្លាប់ដោយសារអត់បាយទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អាហ្នឹងមួយ មួយទៀតញាតិមិត្តជិតខាងក៏គេជួយឧបត្ថមទៀត ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងយើងអត់ខ្លាចទេ អញ្ចឹងមានតែយើងរាល់ថ្ងៃនេះ គំនិតខ្ញុំយើងម្នាក់ៗត្រូវខំធ្វើ ទៅ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បើអត់ជិតខាង ក៏គេមើលឃើញថា យើងខំធ្វើដែរ ហើយធ្វើទៅវាវាំងស្ងួត វាខូច ខាត អត់អញ្ចឹង គេនឹងជួយឧបត្ថមខ្លះហើយ មិនអត់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!

ដានី ៖ អត់ទេ!ខ្ញុំ?

ប៊ុនឡុង ៖ ករណីមួយទៀត ខ្ញុំខ្លាចតែក្រែងបេះ អាហ្នឹងបានជាគាត់លើកហេតុផលថា ខ្លាចអត់ ហូបស្លាប់ ក្រែងគេធ្វើគ្រប់គ្នា គាត់មិនធ្វើ គាត់នៅចាំអង្គុយដូចថា ឈ្មោះ«ក»គាត់ ទៅខំធ្វើស្រែ ធ្វើចំការ គាត់ទៅលក់ទៅ បានលុយទិញម៉ូតូ ទិញកង់ជិះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គាត់គិតតែដើរទៅ ហ៊ី!ចេះ ហ៊ី!ចុះអត់មានធ្វើទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ហើយគាត់រិះគន់គេហើយ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បើគាត់អត់ធ្វើអញ្ចឹង អាហ្នឹងមិនដឹងថាម៉េចទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អាហ្នឹងខ្ញុំមិនហានថាទេ ។

ដានី ៖ បាទៗ!ខ្ញុំអត់ដឹងដែរ ប៉ុន្តែខ្ញុំជួបពូមីងមួយចំនួនគាត់មានប្រសាសន៍អញ្ចឹងដែរ គាត់ថា ហ៊ី!កាលពីមុនដូចថានៅសម័យតស៊ូយើងគិតតែពីតស៊ូយើងនេះទៅ ប៉ុនយើងមានរបប យើងមានគេបើកឲ្យគ្រប់គ្រាន់ ឥឡូវទាល់តែយើងប្រឹងប្រែងទាល់យើងទៅ ធ្វើស្រះ ស្រែងបានអាចបានហូប ជួនខ្លះទៅយើងធ្វើអត់បានទៀត អត់មានពីណាមកជួយ អត់ មានពីណាឲ្យរបបអី?

ប៊ុនឡុង ៖ បាទ!អាជំនាន់នោះគាត់ពឹងផ្អែកទៅលើ អាដែងយើងនិយាយថាមេដឹកនាំមួយៗ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងធម្មតាយើងធ្វើសង្គ្រាម យើងបានទៅធ្វើស្រែបុអត់ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!អត់ទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងអាហ្នឹងហើយ ដែលមេត្រូវការផ្គត់ផ្គង់ជីវភាព ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!តែមកបច្ចុប្បន្ននេះ ដែលសមាហរណកម្មហើយនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងមេ រាជរដ្ឋាភិបាល យើងឥឡូវយើងមានតែមេមួយទេ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ មានតែរាជរដ្ឋាភិបាន អញ្ចឹងរាជរដ្ឋាភិបាលគ្រប់គ្រងខាងអាដែងណែ!ខាងទាហាន ខាង មន្ត្រីរាជការទាំងអស់ដែលធ្វើការបំរើរាជការ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ឯប្រជាពលរដ្ឋគឺគាត់បើកសិទ្ធិឲ្យយើង ធ្វើចំការ ធ្វើស្រែ ឲ្យរកស៊ីផ្សេងៗអីទាំង អស់ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងយើងមិនគួរថា លើកអារឿងអត់មានអ្នកដែងណែ៎នេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ អញ្ចឹងរហូតសម្តេចលោកបាននិយាយថា មិនឲ្យប្រជាពលរដ្ឋម្នាក់ណាស្លាប់ដោយការ អត់ហូបចុកទេ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ អញ្ចឹងភូមិឃុំគេត្រូវប្រយ័ត្នណាស់ អារឿងហ្នឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!អញ្ចឹងយើងអត់ខ្លាចថានេះទេ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ខ្លាចតែរឿងដូចខ្ញុំនិយាយខាងដើមមិញអញ្ចឹង ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ គាត់អត់ធ្វើអី គាត់ចាំតែដើររិះគន់គេ ដើរចុះដើរឡើងអត់តែប្រយោជន៍អញ្ចឹងទៅ ហើយដល់ហើយស្រែកថាអត់ហូប បើអត់ហូបដោយកាលៈទេសៈចាស់ជរា គាត់ធ្វើអី អត់កើតអាហ្នឹងអត់អីទេ តែបើថាកម្លាំងពេញប៊ុបហើយ អត់ធ្វើអី អញ្ចឹងរហូតដល់ អញ្ចឹងខ្ញុំលើអាហ្នឹងបន្តិចចុះ លើកអាហ្នឹងវាវែងហួសបន្តិច ឧទាហរណ៍ថាអ្នក ក្មេងៗ ទីមអាយុ២០ អាយុអីដើរសុំទាន ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ចំណាស់ប្រហែលខ្ញុំធ្វើអីលែងចង់កើតហើយ គាត់មកសុំទាន បានខ្ញុំថាណែ៎ អូនឯង កម្លាំងប៉ុនហ្នឹងណាស់ អញ្ចឹងនៅក្នុងស្រុកនេះ វាមិនអត់របរការងារធ្វើទេ យើងស៊ី ឈ្នួលគេមាថ្ងៃប៉ុន្មាន ១២០០០រៀល ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ ប្អូនឯងទិញបាយហូបអស់ ៦០០០ ប្អូនឯងសន្សំសល់ទុក៦០០០ យើងមិនបាន លុយធ្វើដំណើរទៅវិញហើយ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៈ តែវាចោលពាក្យមកវិញ ខ្ញុំមិនម៉ោស៊ីឈ្នួលទេ ខ្ញុំម៉ោដើរសុំទាន អ៊ឹងឲ្យមិនឲ្យមិនបាច់និយាយលើកទេ ។

ដានី ៈ អ៊ឺ!

ប៊ុនឡុង ៈ ណែ៎! វាចេញពាក្យអញ្ចឹងវិញ ។

ដានី ៈ បាទ! ពូសំនួរចុងក្រោយរបស់ខ្ញុំអ៊ើ! ខ្ញុំចង់ គ្រាន់តែចង់ដឹងពីយោបល់របស់ពូផ្ទាល់ ឥឡូវយើងមានខាងរាជរដ្ឋាភិបាល ហើយអង្គការសហប្រជាជាតិគេបង្កើតតុលាការ តុលាការគេបង្កើតឡើងដើម្បី ជំនុំជំរះទោសមេដឹកនាំជាន់ខ្ពស់ខាងខ្មែរក្រហម ដូចជាមានក្នុងហ្នឹងមាន ពូដឹងហើយឥឡូវហ្នឹងគេកាត់ទោសឌុច ដែលគាត់ជាអតីតប្រធានមន្ទីរស២១ ហើយក្រោយនេះដែលគេ បំរុងនឹងចាប់កាត់ទោសទៀត ដូចជាករណី០០២ មានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ម៉ាចំនួនដូចជា នួន ជា ខៀវ សំផន អៀង សារី ហើយនឹងប្រពន្ធរបស់អៀង សារីហ្នឹង បើតាមយោបល់របស់ពូផ្ទាល់ ពូយល់ឃើញម៉េចដែរ?

ប៊ុនឡុង ៈ បាទ! នេះយោបល់របស់ខ្ញុំ ខ្ញុំឃើញថា បើយើងគិតថាគាត់ពីដើមម៉ោ គាត់ជាអ្នកដឹកនាំមួយ ហើយគាត់ប្រព្រឹត្តដូចថា វាហួសនឹងការស្មាន ហើយហួសអាដែងណែ៎នេះ ត្រូវគេថ្កោលទោស ហើយត្រូវនឹងគេកាត់ទោស អញ្ចឹងអាហ្នឹងករណីគាត់ ដែលគាត់ត្រូវតែទទួលទោសហ្នឹង ។

ដានី ៈ គិតថាត្រឹមត្រូវដែរឬក៏យ៉ាងម៉េច ដូចថាគិតថាគេបង្កើតតុលាការហ្នឹង គេកាត់ទោសពួកគាត់ហ្នឹងត្រឹមត្រូវដែរឬក៏មិនត្រឹមត្រូវ?

ប៊ុនឡុង ៈ បាទ! ខ្ញុំឆ្លើយមួយ តែមួយទេណា៎! ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ! គេបង្កើតច្បាប់ប្រពន្ធ័តុលាការនេះគឺត្រឹមត្រូវណាស់ ។

ដានី ៈ បាទ! អញ្ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំលោកពូទៀតហើយ ពូមានអីចង់បន្ថែមនូវអា អ៊ីដែលខ្ញុំអត់បានសួរនាំលោកពូទេ?

ប៊ុនឡុង ៈ បាទ! មិនមានអីបន្ថែមទៀតទេ គ្រាន់តែថា ខ្ញុំនិយាយទៅនេះ បើសិនជាករណីវាដូចថាចាំបានខ្លះ អត់ខ្លះ អញ្ចឹង១លើកបានតែម៉ាចំនួនអញ្ចឹងទេណា៎ ។

ដានី ៈ បាទ!

ប៊ុនឡុង ៈ បាទ! ព្រោះវាច្រើនឆ្នាំដែរហើយ ។

ដានី ៖ បាទៗ!

ប៊ុនឡុង ៖ បាទ!វាយូរឆ្នាំពេកហើយ អញ្ចឹងខ្ញុំសង្ខេបៗប៉ុណ្ណឹងទេ ព្រោះយើងចាំអត់បានអស់ អញ្ចឹងតាំងពី៧២វាមាវិគ្គសម័យ លន់ ណុល ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ចប់ទាហាន លន់ ណុលទៅ អាហ្នឹងហើយដែលយើងឃើញថាចូលអា ៣ឆ្នាំ ៨ខែ ២០ថ្ងៃ នោះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ ចប់អាហ្នឹងមួយវិគ្គម៉ោ អាដែងណែ!ម៉ាវិគ្គទៀត ជំនាន់មន្ទីររាជរដ្ឋាភិបាល យើងសព្វថ្ងៃនេះ ។

ដានី ៖ បាទ!

ប៊ុនឡុង ៖ បាទ!វាពាជំនាន់ហើយ អញ្ចឹងមិនអាចនេះអស់ទេ អញ្ចឹងបានតែប៉ុណ្ណឹងជូនទេ ។

ដានី ៖ បាទៗ!អញ្ចឹងខ្ញុំអរគុណពូច្រើន ដែលចំណាយពេលផ្ដល់ពត៌មានពីជីវិតរបស់លោកពូដល់ខ្ញុំនេះ ខ្ញុំអរគុណពូច្រើន ។

ប៊ុនឡុង ៖ បាទៗ!ហើយចុងបញ្ចប់សុំឲ្យធ្វើការបន្តឲ្យបានជោគជ័យចុះ ។

ដានី ៖ បាទៗ!អរគុណលោកពូ ។

**ចប់**